# សំណួរ-ចម្លើយ

## ជំនួយស្មារតីចំណោះដឹងវិជ្ជាពលរដ្ឋ ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ




- អ្វីគឺជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ?
- តើត្រូវមានវិធានការពិសេសអ្វីខ្លះ ដើម្បីបង្កើនចំនួនតំណាងរាស្ត្រស្រី នៅអាណត្តិទី៥ នេះ ?
- មុននឹងបោះឆ្នោត តើលោកអ្នកត្រូវពិនិត្យមើលបេក្ខជន-បេក្ខនារី ឈរឈ្មោះដូចម្តេចខ្លះ ?


ចេញផ្សាយ ខែកញ្ញា ឆ្នាំ២០១២

# មាតិកា

**លេខរៀង** **ទំព័រ**


**ផ្នែកទី១:** អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស......................................០១

**ផ្នែកទី២:** ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត...............................................១១

**ផ្នែកទី៣:** ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- សិទ្ធិ និងនីតិវិធី......................................................................១៧
- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត.................................២៣
- យុទ្ធនាការឃោសនាបោះឆ្នោត.....................................................២៦
- នៅថ្ងៃបោះឆ្នោត.......................................................................៣១
- ការរាប់សន្លឹកឆ្នោត....................................................................៤០
- ទោសប្បញ្ញត្តិ និងបណ្តឹង............................................................៤២

**ផ្នែកទី៤:** យេនឌ័រ និងកូតាជាតំណាងអ្នកបោះឆ្នោត..........................................៤៧

**ផ្នែកទី៥:** យុវជន និងនយោបាយ.....................................................................៥៥

**ផ្នែកទី៦:** ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់:......................៥៨
វិមជ្ឈការ វិសហមជ្ឈការ និង អភិបាលកិច្ចមូលដ្ឋាន

# ផ្នែកទី១

# អភិបាលកិច្ចប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស



## ១. តើអភិបាលកិច្ចប្រជាធិបតេយ្យមានន័យដូចម្តេច?

អភិបាលកិច្ចប្រជាធិបតេយ្យ និយាយទៅដល់អភិបាលកិច្ចល្អ បន្ថែមជាមួយគោលការណ៍ បទដ្ឋាន និងស្ថាបន័ប្រជាធិបតេយ្យ ដែលមានន័យថា ៖

- សិទ្ធិមនុស្ស និងមូលដ្ឋានសេរីភាពត្រូវបានគោរព
- ប្រជាពលរដ្ឋមានមតិក្នុងការសម្រេចចិត្ត
- ប្រជាពលរដ្ឋមានសិទ្ធិស្មើភាពប្រាសចាកពីការរើសអើង ហើយស្ត្រីគឺជាដៃគូស្មើភាពជាមួយបុរស ។
- សេចក្តីត្រូវការរបស់មនុស្សជំនាន់ក្រោយត្រូវបានដាក់បញ្ចូលក្នុងគោល-នយោបាយបច្ចុប្បន្ន ។

- គោលនយោបាយ សេដ្ឋកិច្ច និងសង្គម ឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ។

អភិបាលកិច្ចប្រជាធិបតេយ្យមានក្របខ័ណ្ឌដែលគ្របដណ្តប់លើវិស័យចំនួនប្រាំពីរ ÷

១. អភិវឌ្ឍភាព

២. ប្រពន្ធ័ និងដំណើរការបោះឆ្នោត

៣. សិទ្ធិមនុស្ស

៤. យុត្តិធម៌

៥. ការទទួលបាន និងការប្រើប្រាស់ព័ត៌មាន និងការផ្សព្វផ្សាយ

៦. វិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន

៧. កំណែទំរង់រដ្ឋបាលសាធារណៈ និងការប្រឆាំងអំពើពុករលួយ

## ២ៈ អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ?

**លទ្ធិ** : របប ការនិយម ការយល់ឃើញ

**ប្រជា** : ប្រជាជន ប្រជាពលរដ្ឋ

**អធិបតី ឬ អធិបតេយ្យ** : ធំ សម្បើម ក្រៃលែង

លទ្ធិប្រជាធិបតេយ្យជាទម្រង់នៃការដឹកនាំប្រទេសដែលអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋពិតប្រាកដ ។ អំណាចកំពូលក្នុងរដ្ឋ ពិសេស សភា និងរដ្ឋាភិបាលស្ថិតក្នុងកណ្តាប់ដៃប្រជាពលរដ្ឋ ប្រើប្រាស់ដោយប្រជាពលរដ្ឋផ្ទាល់ ឬ/និងដោយអ្នកតំណាងប្រជា-ពលរដ្ឋដែលជ្រើសរើសដោយប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត។ អ្វីៗដែលរដ្ឋាភិបាល និងតំណាងរាស្ត្រធ្វើ គឺត្រូវស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដើម្បីផ្តល់ផលប្រយោជន៍ទៅប្រជាពលរដ្ឋ។ នៅក្នុងរបបប្រជាធិបតេយ្យប្រជាពលរដ្ឋមានអំណាច មានសិទ្ធិសេរីភាពច្រើនបំផុត ។

ជាទស្សនៈទូទៅ រដ្ឋាភិបាល និងរដ្ឋសភាប្រជាធិបតេយ្យ ជារដ្ឋាភិបាល និងសភាដែលកើតឡើងដោយប្រជាពលរដ្ឋ ជារបស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ ។

## ៣. ប្រជាធិបតេយ្យត្រូវបានគេចែកចេញជាប៉ុន្មានប្រភេទ?

ប្រជាធិបតេយ្យ បែងចែកជា**បីប្រភេទ** គឺ*ប្រជាធិបតេយ្យដោយផ្ទាល់ ប្រជាធិបតេយ្យតាមរយៈតំណាង* និង*ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ*។

ក) ***ប្រជាធិបតេយ្យដោយផ្ទាល់ ឬប្រជាធិបតេយ្យសុទ្ធសាធ:*** គឺប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមក្នុងការអនុម័តសេចក្តីសំរេចដោយផ្ទាល់ ឬអនុវត្តសកម្មភាពការងារជាសាធារណៈដោយប្រជាពលរដ្ឋខ្លួនឯង គឺមិនតាមរយៈមន្ត្រីដែលខ្លួនជ្រើសតាំង ឬតែងតាំងឡើយ ។

**ឧទាហរណ៍** : ការធ្វើប្រជាមតិក្នុងការសំរេចអនុមត័ច្បាប់ ឬគោលការណ៍អ្វីមួយ ។

ខ) ***ប្រជាធិបតេយ្យតាមរយៈតំណាង ឬ ប្រជាធិបតេយ្យដោយប្រយោល:*** តាម-រយៈការបោះឆ្នោតជ្រើសរើសអ្នកតំណាងដោយប្រជាពលរដ្ឋ ដើម្បីឱ្យមកធ្វើសេចក្តីសំរេចចិត្តផ្នែកនយោបាយ រៀបចំច្បាប់ និងគោលនយោបាយសំរាប់ផល-ប្រយោជន៍សាធារណៈ ។ ប្រជាធិបតេយ្យតាមរយៈតំណាងនេះ ត្រូវបានគេយកមកអនុវត្តដោយសារតែភាពធំធេង និងសាំញ៉ាំរបស់សង្គមនៅសម័យបច្ចុប្បន្ន ។

**ឧទាហរណ៍:** ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។

***គ) ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ* (Consensus) :** គឺការអនុវត្តដោយការសំរេចតាមរយៈស្រុះស្រួលជាឯកច្ឆន្ទ។ លក្ខណៈនៃការសំរេចចិត្ត គឺផ្តល់ភាពទូលំទូលាយរហូតដល់មតិប្រឆាំង មតិភាគតិច។

**ឧទាហរណ៍:** ប្រជាធិបតេយ្យស្រុះស្រួលជាឯកច្ឆន្ទ (Consensus Democracy) ត្រូវបាន

អនុវត្តនៅក្នុងប្រទេសស្វីស ហ្វាំងឡង់ និងប៊ែលហ្សិក ដែលបានបង្កើតវប្បធម៌នយោបាយស្រុះស្រួលជាឯកច្ឆន្ទ ដោយខិតខំទប់ស្កាត់ការត្រួតត្រាផ្តាច់មុខនៃក្រុមមតិភាគច្រើន។

## ៤. តើធាតុសំខាន់ៗនៅក្នុងប្រជាធិបតេយ្យមានអ្វីខ្លះ?

ធាតុសំខាន់ៗរបស់ប្រជាធិបតេយ្យ ៖

- **សេរីភាពបញ្ចេញមតិ សារព័ត៌មាន និងការប្រជុំ** : ប្រជាពលរដ្ឋមានសិទ្ធិបង្កើតសារព័ត៌មាន វិទ្យុ ទូរទស្សន៍ មានសិទ្ធិទទួល និងផ្សព្វផ្សាយព័ត៌មាន សេរីភាពបង្កើតគណបក្សនយោបាយ អង្គការសង្គម គណៈវិជ្ជាជីវៈ សេរីភាពក្នុងការប្រជុំ និងសេរីភាពធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី។
- **ការបោះឆ្នោត** ដោយសេរី យុត្តិធម៌ សម្ងាត់ និងទៀងទាត់
- **ការផ្ទេរអំណាច** : អ្នកចាញ់ផ្ទេរអំណាចទៅឱ្យអ្នកឈ្នះដោយសន្តិវិធី
- **ពហុនិយម និងការអធ្យាស្រ័យ** : ការសម្រេចអ្វីមួយយកតាមសំលេងភាគច្រើន និងគោរព ពិចារណាលើមតិភាគតិច ។
- **ការបែងចែកអំណាច** (អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ អំណាចតុលាការ): **អំណាច**ត្រូវបែងចែកដាច់ៗពីគ្នា ដោយមិនអនុញ្ញាតឱ្យបុគ្គល ឬស្ថាប័នណាមួយមានអំណាចហួសហេតុ គ្មានការត្រួតពិនិត្យនោះឡើយ។ ការបែងចែកអំណាចសំដៅជាពិសេសដល់ការធានានូវឯករាជភាពរបស់តុលាការ ។

  - **អំណាចនីតិបញ្ញត្តិ** (រដ្ឋសភា និងព្រឹទ្ធសភា): មានមុខនាទីតាក់តែងច្បាប់អនុម័តច្បាប់ និងគោលនយោបាយផ្សេងៗ និងត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល។

  - **អំណាចនីតិប្រតិបត្តិ** (រដ្ឋាភិបាល): មានមុខនាទីអនុវត្តច្បាប់ ធ្វើសេចក្តីព្រាងច្បាប់ ដឹកនាំការងារប្រចាំថ្ងៃរបស់រដ្ឋាភិបាល និងអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចំរើន។

- **អំណាចតុលាការ** : មានមុខនាទីធានាការគោរពច្បាប់ ផ្តល់យុត្តិធម៌សង្គម និងផ្តន្ទាទោសជនណាដែលរំលោភច្បាប់ ។

ការបែងចែកអំណាច ជាគោលនយោបាយមួយសំរាប់វាស់ពីក៏រិតការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការត្រួតពិនិត្យតុល្យភាពនៃអំណាចទាំងការអនុម័ត និងអនុវត្តច្បាប់ ។

- **ការចូលរួមរបស់ប្រជាពលរដ្ឋ** : ការសំរេចចិត្តនានា រួមទាំងការបង្កើតច្បាប់ត្រូវមានការចូលរួមយោបល់ពីប្រជាពលរដ្ឋ និងយកទៅផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹង និងអនុវត្ត ។
- **តម្លាភាព** : ដំណើរការដែលធ្វើឱ្យមានព័ត៌មានពេញលេញដោយសេរី
- **នីតិរដ្ឋ** : រដ្ឋគោរពច្បាប់ រដ្ឋដែលយកច្បាប់ជាធំ ឬដែលមានរដ្ឋាភិបាលគ្រប់គ្រងតាមអំណាចនៃច្បាប់ គឺមិនមែនតាមអំណាចបុគ្គល ឬ ក្រុមបុគ្គលណាមួយឡើយ ។ មន្ត្រីនគរបាល និងតុលាការត្រូវមានវិជ្ជាជីវៈច្បាប់ពិតប្រាកដ ទាំងរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋត្រូវចូលរួមគោរពច្បាប់ទាំងអស់គ្នាដោយស្មើភាព ។

**៥~ អ្វីខ្លះជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development)?**

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាព
- ការពិគ្រោះយោបល់ និងការចូលរួម
- ឆ្លើយតប និងគណនេយ្យភាព
- លើកស្ទួយសមធម៌ (យកចិត្តទុកដាក់ពិសេស ស្ត្រី បុរស យុវជន កុមារ ប្រជាពលរដ្ឋក្រីក្រ ជនពិការ និងជនជាតិដើមភាគតិច) ។
- តម្លាភាព និងសុចរិតភាព

- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

## ៦. អ្វីទៅហៅថាប្រជាធិបតេយ្យូបនីយកម្ម (Democratization)?

ប្រជាធិបតេយ្យូបនីយកម្ម គឺជាអន្តរកាលឆ្ពោះទៅរបបប្រជាធិបតេយ្យពេញលេញ។ មូលហេតុនាំឱ្យមានអន្តរកាល ឬក្នុងដំណើរការប្រជាធិបតេយ្យូបនីយកម្ម គឺបណ្តាលមកពីកត្តាសំខាន់ៗដូចជា ការអប់រំ វណ្ណៈ សង្គមស៊ីវិល ការអន្តរាគមនៃបរទេស មូលធននិយម ។ល។ និង ។ល។

## ៧. អ្វីខ្លះជាប្រជាធិបតេយ្យមានលក្ខណៈពេញលេញ?

ប្រជាធិបតេយ្យត្រូវការឱ្យមានពហុភាព ព្រោះថា មនុស្ស និងក្រុមមនុស្សយើងតែងតែមានជំនឿ និងគំនិតប្លែកៗពីគ្នា។ មនុស្សដែលរស់នៅក្នុងសង្គមប្រជាធិបតេយ្យមិនត្រូវគិតថាមានតែក្រុមខ្លួនទេដែលឈ្នះរហូត ឬថាមានតែក្រុមខ្លួនទេដែលមានគំនិតល្អលើសគេនោះ ពោលគឺត្រូវគិតថា នៅមានក្រុមដទៃទៀតដែលអាចនឹងឈ្នះខ្លួននៅពេលក្រោយ ហើយនៅមានគំនិតនៃក្រុមដទៃទៀតដែលអាចនឹងល្អជាងយើងផងដែរ។ ច្បាប់មតិភាគច្រើនត្រូវតែឈ្នះ និងត្រូវតែការពារគំនិត និងទស្សនៈភាគតិចផង ក៏ដូចគ្នានឹងគណបក្សចាញ់ឆ្នោតត្រូវតែប្រគល់អំណាចទៅគណបក្សដែលឈ្នះឆ្នោតជាដាច់ខាត ព្រោះថាការប្រគល់អំណាចឱ្យនោះគ្រាន់តែជាកាប្រគល់ឱ្យបណ្តោះអាសន្នតែប៉ុណ្ណោះ។គណបក្សចាញ់អាចមានឱកាសត្រឡប់មកកាន់អំណាចវិញនៅពេលបោះឆ្នោតឈ្នះលើកក្រោយ។

*គោលការណ៍ទាំងនេះជាខ្នាតគំរូអន្តរជាតិសំរាប់ឱ្យប្រជាធិបតេយ្យមានលក្ខណៈពេញលេញ :*

(១) **មានការរួមចំណែកពីពលរដ្ឋ** : គឺពលរដ្ឋមិនត្រឹមតែមានសេរីភាព សិទ្ធិទេ ថែមទាំងមានកាតព្វកិច្ចទៀតផង។ ការរួមចំណែករបស់ពលរដ្ឋក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ រួមមាន សេរីភាពបង្កើតសមាគម សហគមន៍ និងគណបក្ស

នយោបាយ សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះបោះឆ្នោត ការបង់ពន្ធដារ ប្រតិបត្តិតាមច្បាប់ និងការឃ្លាំមើលដំណើរការរបស់រដ្ឋាភិបាល សភា និងតុលាការ គឺជាកាតព្វកិច្ចរបស់ពលរដ្ឋដើម្បីជួយកែលំអការអនុវត្តប្រជាធិបតេយ្យ ។

(២) **មានការស្មើភាពគ្នា** : ក្នុងសង្គមប្រជាធិបតេយ្យ គោលការណ៍ស្មើភាពមានន័យថា មនុស្សគ្រប់រូបមានតំលៃ និងមានលទ្ធភាពដូចគ្នា ដោយគ្មានការរើសអើង ។

(៣) **មានការអនុគ្រោះគ្នា** : សង្គមប្រជាធិបតេយ្យ គឺជាសង្គមដែលប្រកបដោយសេចក្តីអនុគ្រោះ។ មានន័យថា ក្នុងពេលដែលគណបក្សឈ្នះ សិទ្ធិគ្រប់គ្រងអំណាចពួកគេត្រូវអនុគ្រោះ និងទទួលស្គាល់សិទ្ធិគ្រប់បែបយ៉ាងរបស់មនុស្សភាគតិច(ឬគណបក្សដែលចាញ់)។ ត្រូវអនុគ្រោះ និងអនុញ្ញាតឱ្យបក្សចាញ់ប្រើសិទ្ធិបញ្ចេញមតិជំទាស់។ រីឯនៅក្នុងសង្គមវិញ មនុស្សម្នាក់ក៏ត្រូវចេះអត់ឱនឱ្យគ្នាទៅវិញទៅមកផងដែរ ។

(៤) **មានការទទួលខុសត្រូវ** : នៅក្នុងសង្គមប្រជាធិបតេយ្យ មន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ ពួកគេត្រូវបំពេញភារកិច្ចតាមឆន្ទៈប្រជាពលរដ្ឋ និងដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ។

(៥) **មានតម្លាភាព** : រឿងអ្វីៗដែលរដ្ឋាភិបាលធ្វើត្រូវតែឱ្យប្រជាពលរដ្ឋបានដឹងឮ នេះមានន័យថា ត្រូវអនុញ្ញាតឱ្យអ្នកកាសែត និងប្រជាពលរដ្ឋសាកសួរព័ត៌មាន អំពីកិច្ចការរបស់រដ្ឋាភិបាល ។

## ៨‐ ប្រព័ន្ធគ្រប់គ្រងរដ្ឋតាមរបបប្រជាធិបតេយ្យមានប៉ុន្មានយ៉ាង?

របបផ្តាច់ការ របបកុម្មុយនីស និងរបបហ្វាស៊ីស មិនមែនជារបបប្រជាធិបតេយ្យទេ។

**ប្រព័ន្ធគ្រប់គ្រងរដ្ឋតាមប្រជាធិបតេយ្យមាន ៣ យ៉ាង គឺ :**

- **ប្រព័ន្ធប្រធានាធិបតីនិយម** : ប្រធានាធិបតីត្រូវបានបោះឆ្នោតជ្រើសរើសដោយ

ប្រជាពលរដ្ឋ, មិនមាននាយករដ្ឋមន្ត្រីទេ ដូចជា សហរដ្ឋអាមេរិក, ហ្វីលីពីន, ឥណ្ឌូនេស៊ី ... ( អំណាចសភា និងរដ្ឋាភិបាលដាច់ពីគ្នា ) ។

- **ប្រពន្ធ័សភានិយម** : រដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជា-ពលរដ្ឋ ហើយរដ្ឋសភាបោះឆ្នោតទុកចិត្តនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលទាំងមូល ដូចជា*កម្ពុជា ជប៉ុន ថៃ អង់គ្លេស...*។ មានតែនាយករដ្ឋមន្ត្រី មិនមានប្រធានាធិបតីទេ ( អំណាចសភា និងរដ្ឋាភិបាលមានតុល្យភាពគ្នា ) ។
- **ប្រពន្ធ័ចំរុះ** : ប្រធានាធិបតី ត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ហើយប្រធានាធិបតីតែងតាំងនាយករដ្ឋមន្ត្រី ដូចជា បារាំង និងរុស្ស៊ី ( មានប្រធានា-ធិបតីផង និងនាយករដ្ឋមន្ត្រីផង ) ។

## ៩. តើប្រទេសកម្ពុជាប្រកាន់យករបបនយោបាយ និងប្រព័ន្ធអ្វី?

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយ***ប្រជាធិបតេយ្យ សេរី ពហុបក្សតាមប្រពន្ធ័សភានិយម***។

## ១០. ប្រទេសដែលមាននីតិរដ្ឋ ត្រូវមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ?

ប្រទេសដែលមាននីតិរដ្ឋ លុះត្រាតែប្រទេសនោះប្រកបដោយលក្ខខណ្ឌចាំបាច់ដូចតទៅ :

- ត្រូវមានតុលាការប្រកបដោយសមត្ថភាព វិជ្ជាជីវៈ ឥតលំអៀង និងឯករាជ្យពិតប្រាកដ មិនស្ថិតក្រោមអំណាចបុគ្គល ឬក្រុមណាមួយ ។
- អ្នកគ្រប់គ្រងត្រូវប្រើប្រាស់អំណាចខ្លួនឱ្យស្របទៅតាមច្បាប់ មិនរំលោភអំណាច ឬយកអំណាចនោះទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ខ្លួន និងបក្សពួក ថែមទាំងមិនជ្រៀតជ្រែកទៅក្នុងការងារតុលាការជាដើម ។
- ត្រូវមានរដ្ឋធម្មនុញ្ញចែងទុកជាមុន អំពីការប្រើសិទ្ធិពេញលេញក្នុងការត្រួត-ពិនិត្យអំណាចនីតិប្រតិបត្តិ និងរដ្ឋបាល ដើម្បីកុំឱ្យអំណាចទាំងនេះរំលោភច្បាប់ ។

- ប្រជាពលរដ្ឋត្រូវមានសមភាពចំពោះមុខច្បាប់ទាំងអស់គ្នា មានន័យថាប្រជាពលរដ្ឋគ្រប់រូប គ្រប់ជាន់ថ្នាក់ ត្រូវមានសិទ្ធិយករឿងក្ដីខ្លួនទៅប្ដឹងផ្ដល់ដល់សាលាជម្រះក្ដី និងបានទទួលការវិនិច្ឆ័យដោយយុត្តិធម៌ដូចៗគ្នា។
- សេរីភាពសារព័ត៌មាន ៖ ប្រជាពលរដ្ឋត្រូវទទួលសិទ្ធិ និងសេរីភាពយ៉ាងពេញលេញក្នុងការបញ្ចេញមតិ យោបល់ បង្កើតអង្គការសារព័ត៌មាន ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ជាលក្ខណៈឯកជន ។

**១១. សិទ្ធិមនុស្សជាមូលដ្ឋានមានអ្វីខ្លះ?**

**ក. សិទ្ធិពលរដ្ឋ ៖**

- សិទ្ធិរស់រានមានជីវិត
- សេរីភាពខាងជំនឿ និងមនសិការផ្ទាល់ខ្លួន
- សេរីភាពក្នុងការបញ្ចេញមតិ និងចូលរួមសមាគម
- សិទ្ធិធ្វើដំណើរដោយសេរី (ប៉ុន្តែបើចូលទៅប្រទេសដទៃត្រូវមានការអនុញ្ញាតពីអាជ្ញាធរនៃប្រទេសនោះ) ។
- សិទ្ធិតាំងទីលំនៅដោយសេរី (ប៉ុន្តែត្រូវឱ្យសមស្របតាមច្បាប់សំណង់)
- សិទ្ធិការពារការរំលោភបំពានលើរាងកាយ និងផ្លូវចិត្ត
- ភាពស្មើគ្នាចំពោះមុខច្បាប់ និងតាមផ្លូវតុលាការ
- សិទ្ធិការពារការឆែកឆេរលំនៅដ្ឋានខុសច្បាប់
- សិទ្ធិរួចចាកផុតពីអំណាចផ្ដាច់ការរបស់រដ្ឋាភិបាល និងមានការការពារពីច្បាប់។

**ខ. សិទ្ធិនយោបាយ ៖**

- សេរីភាពក្នុងការនិយាយស្ដី សារព័ត៌មាន ប្រជុំធ្វើសេចក្ដីតវ៉ា
- សិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត

- សិទ្ធិចូលរួមបោះឆ្នោតដោយសេរី តាមឆន្ទៈ និងគ្មានការភ័យខ្លាច
- សេរីភាពបង្កើតសមាគម ឬ គណបក្សនយោបាយ
- សិទ្ធិចូលរួមក្នុងឆាកនយោបាយ (សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ សិទ្ធិចូលរួមក្នុងគណបក្សនយោបាយ និងសិទ្ធិលាឈប់ពីសមាជិកគណបក្សនយោបាយ) ។
- សិទ្ធិមានលទ្ធភាពស្មើគ្នាចំពោះសេវាកម្មសាធារណៈ (រួមទាំងសិទ្ធិទទួលការជ្រើសរើសឱ្យកាន់តំណែងការងារ) ។

**គ. សិទ្ធិសេដ្ឋកិច្ច និងសង្គម :**

- សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន (ការដាក់ជាសម្បត្តិរួមដូចសម័យខ្មែរក្រហម គឺជាការរំលោភ) ។
- សិទ្ធិទទួល (ដោយទិញជូន ឬអំណោយប្រើប្រាស់ ផ្ទេរ និងឱ្យទៅគេដោយលក់ដូរ ឬធ្វើអំណោយ ឬបោះបង់ចោលនូវទ្រព្យសម្បត្តិ) ។
- សិទ្ធិជ្រើសរើសការងារ ឬផ្លាស់ប្តូរការងារ (មិនបង្ខំឱ្យធ្វើការងារដោយផ្ទុយនឹងឆន្ទៈ ឬផ្ទុយពីសមត្ថភាព និងមុខជំនាញឡើយ) ។
- សិទ្ធិចូលរួមក្នុងសហជីព សមាគមវិជ្ជាជីវៈ សិទ្ធិធ្វើមុខជំនួញ និងសិទ្ធិធ្វើកិច្ចសន្យាស្របច្បាប់ ។
- សិទ្ធិមានម្ហូបអាហារគ្រប់គ្រាន់
- សិទ្ធិមានគ្រួសារ និងគូស្រករ
- សិទ្ធិមានសន្តិសុខសង្គម
- សិទ្ធិមានពេលសំរាក និងកំសាន្តកាយ (ជនណាក៏ដោយមានសិទ្ធិធ្វើការមានកំណត់ពេលម៉ោងត្រឹមត្រូវ និងមានពេលសំរាកកំសាន្ត) ។

- សិទ្ធិទទួលការអប់រំ ( មនុស្សគ្រប់រូបត្រូវតែមានចំណេះដឹង។ សង្គម និងរដ្ឋមានកាតព្វកិច្ចចាំបាច់ធ្វើឱ្យពលរដ្ឋគ្រប់រូបបានរៀនសូត្រ) ។

**ឃ. សិទ្ធិវប្បធម៌ :**

- សិទ្ធិដើម្បីមានចំណេះដឹង និងសិទ្ធិអាស្រ័យផលវប្បធម៌ និងរក្សាសិទ្ធិ
- សិទ្ធិនិយាយភាសាដើមរបស់ខ្លួន និងសិទ្ធិប្រកាន់ទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនារបស់ខ្លួន ។



**ង. សិទ្ធិមានបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍**

- សិទ្ធិរស់នៅក្នុងបរិស្ថានមួយបរិសុទ្ធ
- សិទ្ធិការពារការបំផ្លិចបំផ្លាញបរិស្ថាន និងសិទ្ធិអភិវឌ្ឍន៍សហគមន៍ ។

# ផ្នែកទី២: ការបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត

## ១២. អ្វីគឺជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌?

**ការបោះឆ្នោតដោយសេរី :**

គឺនិយាយទៅដល់សេរីភាព សិទ្ធិ ឱកាស និងលទ្ធភាព ។



- **ការបោះឆ្នោត និងសិទ្ធិចូលរួមបោះឆ្នោត**
- ពុំមានពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ត្រូវបានគេបដិសេធមិនឱ្យបោះឆ្នោត ឬត្រូវបានបង្កការលំបាកក្នុងការបោះឆ្នោតដែលបាត់បង់ឱកាសបោះឆ្នោត ។
- អ្នកបោះឆ្នោតមានសិទ្ធិស្មើគ្នានៅក្នុងស្ថានីយ៍ ឬការិយាល័យបោះឆ្នោតដើម្បីប្រើប្រាស់

សិទ្ធិបោះឆ្នោតរបស់ខ្លួន។

- សិទ្ធិបោះឆ្នោតជាសំងាត់ ជាសិទ្ធិដាច់ខាត
- អ្នកបោះឆ្នោតគ្រប់រូបត្រូវមានលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ហើយមានសំលេងស្មើគ្នានឹងសំលេងឆ្នោតរបស់អ្នកឯទៀត។
- ប្រជាពលរដ្ឋពេញវ័យគ្រប់រូបមានសិទ្ធិបោះឆ្នោតដោយគ្មានការរើសអើង
- អ្នកបោះឆ្នោតអាចទទួលព័ត៌មានអំពីដំណើរការបោះឆ្នោតដោយសេរី និងគ្រប់ដំណើរការនៃការបោះឆ្នោត។
- មានការចូលរួមប្រជុំដោយសេរី និងការបញ្ចេញមតិយោបល់ ដើម្បីពិភាក្សាអំពីបេក្ខជន បេក្ខនារី និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។
- អ្នកបោះឆ្នោតសំរេចចិត្តបោះឆ្នោតតាមឆន្ទៈរបស់ខ្លួនពិតប្រាកដ ដោយគ្មានការគំរាមកំហែង គ្មានការបង្ខំឱ្យបោះឆ្នោតគាំទ្រគណបក្សណាមួយ គ្មានការទិញសន្លឹកឆ្នោត គ្មានអំពើហឹង្សា។

■ **ដំណើរការបោះឆ្នោត បេក្ខជន និងគណបក្សនយោបាយ**

- ប្រជាពលរដ្ឋមានសិទ្ធិ និងឱកាសស្មើគ្នាក្នុងការឈរឈ្មោះជាបេក្ខជន។ បេក្ខជនគ្រប់រូប និងគណបក្សទាំងអស់ត្រូវមានឱកាសស្មើគ្នា ដើម្បីប្រើប្រាស់ប្រពន្ធ័ឃោសនា និងមានសិទ្ធិក្នុងបញ្ហាសន្តិសុខដោយគ្មានការគំរាមកំហែង ការបំភិតបំភ័យ និងមានសិទ្ធិធ្វើសកម្មភាពឃោសនាដោយសេរី គ្មានការរារាំង ការរំខាន និងមានសុវត្ថិភាព។ គណបក្សអាចពង្រីកបណ្តាញ និងជ្រើសរើសសមាជិកសកម្មជនដោយសេរី។
- បុគ្គលគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិឱ្យច្បាប់ការពារ ហើយមានសិទ្ធិឱ្យមានការដោះស្រាយការរំលោភនានាលើសិទ្ធិនយោបាយ និង

សិទ្ធិបោះឆ្នោត ។

- **អ្នកសង្កេតការណ៍**

  - អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងារបស់គណបក្សនយោបាយ ត្រូវបានផ្តល់សិទ្ធិដើម្បីចូលរួមសង្កេតការណ៍ តាមដាន និងធ្វើរបាយការណ៍លើរាល់សកម្មភាពនៃដំណើរការបោះឆ្នោតបានដោយសេរី និងទូលំទូលាយ ។

**ការបោះឆ្នោតដោយយុត្តិធម៌:**

គឺនិយាយទៅដល់ការទទួលខុសត្រូវ និងកាតព្វកិច្ច ។

- មិនមានការក្លែងបន្លំសន្លឹកឆ្នោត ឬការលួចដូរសន្លឹកឆ្នោត គ្មានការប្រើប្រាស់មធ្យោបាយទុច្ចរិតផ្សេងៗ ។
- អាជ្ញាធររៀបចំការបោះឆ្នោតឯករាជ្យ អព្យាក្រឹត ស្អាតស្អំ តម្លាភាព និងមានការជឿជាក់ពីសាធារណជន ។
- មានប្រព័ន្ធបោះឆ្នោតល្អ មាននិយ័តភាព (ការបោះឆ្នោតត្រូវធ្វើឡើងដោយទៀងទាត់ក្នុងរយៈពេលកំណត់ប្រាំឆ្នាំម្តង) ។
- ការដោះស្រាយវិវាទបោះឆ្នោតមានភាពយុត្តិធម៌ ត្រឹមត្រូវតាមច្បាប់ មានតម្លាភាព
- បង្កើតលក្ខខណ្ឌប្រកួតប្រជែងសម្រាប់បោះឆ្នោតដោយផ្អែកលើមូលដ្ឋានដែលមាន "សមធម៌" ។
- បង្កើតនីតិវិធីដ៏មានប្រសិទ្ធភាព ឥតលំអៀង និងឥតមានការរើសអើងសម្រាប់ការចាត់ចែងការបោះឆ្នោត ពិសេសការចុះឈ្មោះបោះឆ្នោត និងការឃោសនាបោះឆ្នោត ។
- ធានាឱ្យបាននូវភាពទៀងត្រង់ក្នុងការបោះឆ្នោត ពិសេសថ្ងៃបោះឆ្នោត ដែលអ្នកបោះឆ្នោតណាម្នាក់បោះឆ្នោតបានច្រើនលើក ឬការបោះឆ្នោតដោយជនទាំងឡាយណាដែលគ្មានឈ្មោះក្នុងបញ្ជី ។

- ធានាឱ្យគណបក្ស បេក្ខជន និងអ្នកគាំទ្រ មានសន្តិសុខដូចៗគ្នា ។

## ១៣. លក្ខណៈបែបណាខ្លះដែលជាការបោះឆ្នោតដោយស្មើភាព?

- គណបក្សនយោបាយ និងបេក្ខជនទាំងអស់មានឱកាសស្មើគ្នាក្នុងការប្រកួតប្រជែង
- នៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត គណបក្សនយោបាយចូលរួមប្រកួតប្រជែងទាំងអស់ស្មើភាពគ្នាក្នុងការប្រើប្រាស់ប្រពន្ធ័ផ្សព្វផ្សាយរដ្ឋ ដូចជា ទូរទស្សន៍ វិទ្យុ មានសិទ្ធិប្រើសេវាសាធារណៈដូចៗគ្នា អាចប្រើសិទ្ធិរួមប្រជុំមហាជនតាមកន្លែងសាធារណៈតាមគ្រប់រូបភាព និងមធ្យោបាយដោយស្មើភាពគ្នា ដើម្បីបង្ហាញពីកម្មវិធីនយោបាយ និងសមត្ថភាពរបស់ខ្លួនជូនប្រជាពលរដ្ឋ ។
- អ្នកបោះឆ្នោតមានសិទ្ធិបោះឆ្នោតបានតែ១ដងគត់ ស្មើនឹង១សន្លឹក ក្នុង១អាណត្តិ ។ សន្លឹកឆ្នោត១សន្លឹកមានតម្លៃស្មើគ្នានៅគ្រប់មណ្ឌលបោះឆ្នោត ខេត្ត ក្រុង ឃុំ សង្កាត់ទាំងអស់ ទោះបីអ្នកបោះឆ្នោតមានឋានៈជានាយករដ្ឋមន្ត្រី អភិបាលខេត្ត អភិបាលស្រុក ជាព្រះសង្ឃ ជាមេឃុំ ឬប្រជាពលរដ្ឋសាមញ្ញក៏ដោយ ។

## ១៤.តើអ្នកបោះឆ្នោតប្រើប្រាស់សិទ្ធិអំណាចយ៉ាងណាចំពោះតំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណបក្សជាប់ឆ្នោត?

- ♦ ក្រោយពេលបោះឆ្នោត អ្នកបោះឆ្នោតត្រូវតែតាមដាន សង្កេត និងវាយតម្លៃលើសកម្មភាព និងការអនុវត្តការសន្យារបស់អ្នកតំណាងជាប់ឆ្នោតរបស់ខ្លួន និងគណបក្សជាប់ឆ្នោត។ អ្នកតំណាងដែលជាប់ឆ្នោត (តំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់) បានទទួលអំណាចពីប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត ត្រូវតែបំរើផលប្រយោជន៏ និងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។
- ♦ បើអ្នកតំណាងជាប់ឆ្នោតមិនបានបំរើផលប្រយោជន៏ប្រជាពលរដ្ឋ មិនអនុវត្តតាមការសន្យារបស់ខ្លួន ប្រជាពលរដ្ឋអាចប្រើប្រាស់អំណាចរបស់ខ្លួន ដោយស្នើសុំឱ្យ

អ្នកតំណាងនោះគោរពការសន្យារបស់ខ្លួន ឬសុំឱ្យអ្នកតំណាងនោះលាចេញពីតំណែងមុនពេលកំណត់ ឬប្រជាពលរដ្ឋអាចធ្វើពាក្យបណ្តឹងទៅសាមីគណបក្សនយោបាយនៃអ្នកតំណាងនោះនៅអាណត្តិក្រោយឱ្យធ្វើការផ្លាស់ប្តូរអ្នកតំណាងរូបនោះចេញ ឬជំរើសចុងក្រោយប្រជាពលរដ្ឋមិនបោះឆ្នោតគាំទ្រអ្នកតំណាងរូបនោះ ឬគណបក្ស នយោបាយរបស់អ្នកតំណាងនោះ ហើយប្រជាពលរដ្ឋបោះឆ្នោតឱ្យអ្នកតំណាងថ្មីផ្សេងទៀតដែលខ្លួនពេញចិត្ត សង្ឃឹមថាអាចដោះស្រាយបញ្ហាយើងបាន។

♦ ប្រសិនបើកំហុសរបស់អ្នកតំណាង (ជាបុគ្គល ឬគណបក្សនយោបាយ) មានលក្ខណៈធ្ងន់ធ្ងរ ដូចជា ការកេងប្រវ័ញ្ចជាតិ អំពើពុករលួយធ្ងន់ធ្ងរមិនដោះ-ស្រាយបញ្ហាជាតិ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដូចជាការសំលាប់មនុស្ស។ល។ ក្នុងអាណត្តិដែលខ្លួនមានអំណាច ប្រជាពលរដ្ឋត្រូវប្រើសិទ្ធិអំណាចខ្លួន អំពាវនាវប្តឹងទៅសភា ព្រឹទ្ធសភា តុលាការឯករាជ្យ ឬប្រើប្រាស់សិទ្ធិបញ្ចេញមតិ និងមហាបាតុកម្មដោយសន្តិវិធី ដើម្បីឱ្យដកអភ័យឯកសិទ្ធិ និងចោទប្រកាន់ដាក់ទោសទណ្ឌកម្ម។

## ១៥. តើលោក អ្នកត្រូវដោះស្រាយយ៉ាងណា នៅពេលជួប ឬប្រឈមមុខជាមួយនឹងឧបាយកលទុច្ចរិតក្នុងដំណើរការបោះឆ្នោត?

ឧបាយកលទុច្ចរិតមានដូចជា : ការគំរាមកំហែង ការបំភិតបំភ័យ ការទិញសន្លឹកឆ្នោត(ដោយសម្ភារៈ ឬប្រាក់កាស) ការលួងលោមទិញទឹកចិត្ត ការបង្ខំឱ្យធ្វើសម្បថការកត់លេខឯកសារបញ្ជាក់អត្តសញ្ញាណ។ល។ និង។ល។

ប្រជាពលរដ្ឋត្រូវរាយការណ៍ជាសម្ងាត់ដល់អ្នកសង្កេតការណ៍ ឬ ភ្នាក់ងាររបស់គណបក្សនយោបាយ ដែលលោកអ្នកទុកចិត្ត។ ប៉ុន្តែ បើលោកអ្នកជួបបញ្ហាចំពោះមុខ

គេកំពុងគំរាមកំហែង លោក អ្នកត្រូវដោះស្រាយដោយភាពទន់ភ្លន់ ដូចជា ÷

- បើលោក អ្នកនិយាយទៅដោយគ្មានផលវិបាក ឬគ្រោះថ្នាក់ដល់ខ្លួនទេនោះ លោក អ្នកអាចនិយាយថា " ***ក្នុងពេលនេះខ្ញុំពុំទាន់ធ្វើការសំរេចចិត្តនៅឡើយទេ សូមអភ័យទោស*** " ។

- បើចៀសមិនរួច លោក អ្នកត្រូវតែទទួលយក គួរប្រើពាក្យយ៉ាងទន់ភ្លន់ថា " ***ខ្ញុំនឹងបោះឆ្នោតឱ្យលោក ឬគណបក្សរបស់ លោក*** " ។

**ប៉ុន្តែ** ប្រការដែលត្រូវចងចាំនោះគឺ ការបោះឆ្នោតជា **ការសម្ងាត់** គ្មានអ្នកណាដឹងថាលោក អ្នកបោះឆ្នោតឱ្យគណបក្សណាមួយទេ។ ដូចនេះ លោក អ្នកត្រូវបោះឆ្នោត **តាមឆន្ទះ និងការពេញចិត្ត**របស់ខ្លួន។

## ១៦- តើអ្វីខ្លះជាភារកិច្ចរបស់អ្នកបោះឆ្នោត?

- អ្នកបោះឆ្នោត ត្រូវ/ចេះស្វះស្វែង ព្យាយាមតាមដានដោយយកចិត្តទុកដាក់រាល់ការអប់រំ ផ្សព្វផ្សាយ ផ្តល់ព័ត៌មានអំពីការបោះឆ្នោតរបស់ស្ថាប័នរៀបចំការបោះឆ្នោត សមាគម-អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងចេះអប់រំ ផ្សព្វផ្សាយបន្តដល់បងប្អូនប្រជាពលរដ្ឋជិតខាង និងមិត្តភក្តិរបស់ខ្លួន ។
- អ្នកបោះឆ្នោតចេះដោះស្រាយនូវបញ្ហានានា (ឧបាយកលទុច្ចរិត) ពេលដែលខ្លួនជួប ឬប្រឈមមុខក្នុងអំឡុងពេលបោះឆ្នោតដោយសន្តិវិធី ដោយភាពវៃឆ្លាត ដើម្បីសុវត្ថិភាព។
- ពិនិត្យមើលបុគ្គលិកលក្ខណៈរបស់បេក្ខជន បេក្ខនារីឈរឈ្មោះ និងគោលនយោបាយ/កម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗ។
- បោះឆ្នោតតាម**ឆន្ទៈ**របស់ខ្លួន ទោះបីគេគំរាមកំហែង យកសំភារៈ ឬលុយទិញទឹកចិត្ត បង្ខំឱ្យធ្វើសម្បថ ឬប្រើសកម្មភាពបង្ខិតបង្ខំយ៉ាងណាក៏ដោយ ដោយលោក អ្នកត្រូវយល់ពីគោលការណ៍នៃការបោះឆ្នោត " **បោះឆ្នោតដោយសំងាត់ តាមឆន្ទៈ**

**ដោយសេរី និងស្មើភាព** ”។




# ផ្នែកទី៣

## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅកម្ពុជា៖
## សិទ្ធិ និងនីតិវិធី

### ១៧. តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រគឺជាអ្វី?

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺជាដំណើរការជ្រើសរើសសភាថ្នាក់ជាតិ (រដ្ឋសភា)ដែលមានសមាជិកសភា ឬអ្នកតំណាងរាស្ត្រពី ១នាក់-១៨នាក់ (១អាសនៈ-១៨អាសនៈ)ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្រ ដោយប្រជាពលរដ្ឋនៃរាជធានី ខេត្ត របស់ខ្លួន (រាជធានី ខេត្តជាមណ្ឌលបោះឆ្នោត) តាមរយៈការបោះឆ្នោតជា សកល មានអាណត្តិ៥ឆ្នាំ ដោយសេរី ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

### ១៨. តើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកនេះ ជាអាណត្តិទីប៉ុន្មាន?

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកនេះ(ឆ្នាំ២០១៣)គឺជា **អាណត្តិទី៥ (ឆ្នាំ២០១៣-២០១៨)** នៃរដ្ឋសភា/តំណាងរាស្ត្រ ដែលមានអាសនៈសរុបចំនួន ១២៣។

## ១៩. តើនឹងមានអ្វីកើតឡើង បើសិនជាលោក អ្នកមិនបានទៅបោះឆ្នោត?

**លោក អ្នកត្រូវតែទៅបោះឆ្នោត!** ការបោះឆ្នោតមានសារៈសំខាន់ណាស់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្តរបស់ប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោត។ បើលោកអ្នកមិនទៅបោះឆ្នោតទេ មានន័យថា អ្នកដទៃជាអ្នកសំរេចចិត្តក្នុងការជ្រើសរើសអ្នកដឹកនាំជំនួសលោកអ្នក ហើយក៏មានន័យថា លោកអ្នកបានបោះបង់សិទ្ធិជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។ ម្យ៉ាងទៀត មានន័យថា លោកអ្នកបណ្តោយឱ្យអ្នកជាប់ឆ្នោតធ្វើអ្វីតាមតែអំពើចិត្ត មិនបំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋហើយប្រទេសជាតិគ្មានការរីកចំរើន។

ដូចនេះ លោកអ្នកត្រូវតែទៅបោះឆ្នោតជ្រើសរើស អ្នកដឹកនាំឱ្យបានត្រឹមត្រូវដើម្បីអភិវឌ្ឍប្រទេសជាតិ ព្រោះវាជាសិទ្ធិ និងករណីយកិច្ចរបស់លោកអ្នក និងជាឱកាសដ៏ល្អរបស់លោកអ្នកក្នុងការជ្រើសរើសអ្នកដឹកនាំដែលខ្លួនពេញចិត្ត។

កំលាំងចូលរួមរបស់លោកអ្នកក្នុងការបោះឆ្នោត និងជាមួយតំណាងដែលជាប់ឆ្នោត ប្រៀបដូចជាតំណក់ទឹកបំបែកផ្ទាំងសិលាមួយដ៏ធំ និងជាកំលាំងចលករជំរុញឱ្យមានការដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមមួយថ្ងៃបន្តិចៗ ដើម្បីពួកយើង កូនចៅជំនាន់ក្រោយ និងប្រទេសជាតិមានប្រជាធិបតេយ្យរឹងមាំ ។

## ២០. តើលោក អ្នកត្រូវតែចូលជាសមាជិករបស់គណបក្សនយោបាយណាមួយឬទេដើម្បីបានទៅបោះឆ្នោត ?

**<u>មិនចាំបាច់ទេ</u>** ! ការបោះឆ្នោតគឺជាសិទ្ធិនយោបាយ និងជាសេរីភាពរបស់លោកអ្នក។ ដូចនេះ លោក អ្នក<u>មិនចាំបាច់</u>ចូលជាសមាជិកគណបក្សនយោបាយណាមួយឡើយ។ ទោះបីលោក អ្នកមិនមែនជាសមាជិកគណបក្សនយោបាយណាមួយក៏ដោយក៏លោក អ្នកមានសិទ្ធិបោះឆ្នោតដោយសេរីបានដែរ។

## ២១. មុននឹងបោះឆ្នោត តើលោក អ្នកត្រូវពិនិត្យមើលបេក្ខជន បេក្ខនារីឈរឈ្មោះដូចម្តេចខ្លះ?

※ ដំបូងត្រូវពិនិត្យមើលបេក្ខជន-បេក្ខនារីឈរឈ្មោះក្នុងបញ្ជីគណបក្ស ថាតើមានដាក់បេក្ខជន-បេក្ខនារីឆ្លាស់គ្នានៅលេខរៀងខាងលើឬទេ?(អ្នកនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ឆ្នោតច្រើន) ហើយមានលក្ខណៈសម្បត្តិយ៉ាងណាខ្លះ?

※ បន្ទាប់មកបេក្ខជន-បេក្ខនារីនោះធ្លាប់ឈរឈ្មោះឬទេនៅអាណត្តិមុនៗ

※ បើគាត់ធ្លាប់ឈរឈ្មោះ តើបានជាប់ឆ្នោតឬទេ? ជាប់ឆ្នោតជាអ្វី(ជាក្រុមប្រឹក្សាឃុំសង្កាត់ ឬតំណាងរាស្ត្រ)?

※ នៅពេលគាត់ជាប់ឆ្នោតក្នុងតំណែង តើគាត់យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋក៏រិតណា? ហើយគួរបោះឆ្នោតឱ្យគាត់បន្តទៀតឬមួយយ៉ាងណា?

※ បើគាត់មិនធ្លាប់ឈរឈ្មោះ តើគាត់ធ្លាប់ធ្វើការជាអ្វី (មន្ត្រីរាជការ គ្រូបង្រៀនពេទ្យ អាចារ្យ អ្នករកស៊ី)?

※ ពេលពួកគាត់នៅធ្វើការ តើពួកគាត់ធ្វើការល្អឬទេ? យកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋឬទេ?

※ បន្ទាប់មក ត្រូវពិនិត្យថា បេក្ខជន-បេក្ខនារីធ្លាប់រកស៊ីខុសច្បាប់ បន្លំ ឆបោក ទារប្រាក់ពីប្រជាពលរដ្ឋ ឬប្រព្រឹត្តិអំពើហឹង្សាក្នុងគ្រួសារ ឬឈ្លោះទាស់ទែងជាមួយអ្នកជិតខាងដោយមិនសមរម្យ រំលោភយកដីប្រជាពលរដ្ឋ ឬមានបញ្ហាផ្សេងៗទៀត។

※ តើគាត់មានគំនិតទូលំទូលាយ យល់ដឹងអំពីប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សគំនិតអធ្យាស្រ័យ ដោះស្រាយបញ្ហាដែរឬទេ?

※ តើគាត់មានការប្តេជ្ញាចិត្តក្នុងការលើកយកបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋដាក់ជូនរដ្ឋាភិបាលឬទេ?

※ តើគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំប្រទេសជាតិឱ្យរីកចំរើនបានឬទេ?




## ២២. តើអ្នកបោះឆ្នោត ត្រូវស្វែងយល់អំពីកម្មវិធីនយោបាយរបស់គណបក្សឬទេ ?

**ត្រូវតែស្វែងយល់** ! ព្រោះបេក្ខជន/បេក្ខនារីគឺជាសមាជិកគណបក្សនយោបាយ!

- ត្រូវពិនិត្យមើលគោលជំហរ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ថាតើមាននិន្នាការទៅរកប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច(ចង់ឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារឬទុកឱ្យប្រជាពលរដ្ឋនៅក្រីក្រ) ការគោរពសិទ្ធិមនុស្ស ការនិយមលទ្ធិផ្តាច់ការ ការប្រើប្រាស់អំណាចហួសហេតុ(ការតែងតាំង ការដកបុគ្គលិក) ការប្រព្រឹត្តិអំពើពុករលួយ និងថាតើមានលើកយកវិធានការដោះស្រាយបញ្ហាស្ត្រី និងកុមារដែរឬទេ?
- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ ការអនុវត្តតាមការសន្យា
- ការរៀបចំរចនាសម្ព័ន្ធក្នុងគណបក្សមានលក្ខណៈប្រជាធិបតេយ្យ មានការផ្លាស់ប្តូរប្រធានគណបក្សឬទេ? មានការបោះឆ្នោតផ្ទៃក្នុងគណបក្សឬទេ? និងមានគោល-នយោបាយយេនឌ័រលើកកំពស់សិទ្ធិនារីឬទេ?

- តើអ្នកដឹកនាំគណបក្សនោះជានរណា?

## ២៣. តើអ្វីខ្លះជាផលវិបាកនៃការទិញលក់សន្លឹកឆ្នោត?

ប្រសិនបើលោក អ្នកបោះឆ្នោតដោយការទិញ លក់សន្លឹកឆ្នោតនោះវាធ្វើឱ្យ ៖

- លោក អ្នក ក្លាយជាទាសករនៃអំណាច
- លោក អ្នកត្រូវគិតថា ជំនួយតែងមានចំណង ដូចពាក្យចាស់លោកពោលថា ***"ហុចរបស់ស្រណោះដៃ"*** ។
- បើលោក អ្នកបោះឆ្នោតតាមការ**ទិញ**សន្លឹកឆ្នោត យើងនឹងបានអ្នកជាប់ឆ្នោតជាតំណាងមិនល្អ ប្រើប្រាស់អំណាចហួសហេតុ ប្រព្រឹត្តអំពើពុករលួយដើម្បីបានប្រាក់យកមកទិញសន្លឹកឆ្នោតនៅពេលបោះឆ្នោតលើកក្រោយទៀតហើយកាន់អំណាចជារៀងរហូត
- បើយើង**លក់**សន្លឹកឆ្នោត យើងនៅតែក្រីក្រ គ្មានការអភិវឌ្ឍនៅមណ្ឌល ឬប្រទេសជាតិរបស់យើង អ្នកកាន់អំណាចមិនបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រកបរបររកស៊ី និងការងារ ។
- សង្គមមានការរំលោភច្បាប់បោះឆ្នោត មិនគោរពសិទ្ធិមនុស្ស គ្មានប្រជាធិបតេយ្យ គ្មានយុត្តិធម៌ មានអំពើពុករលួយ គ្មានការអភិវឌ្ឍ និងបន្តភាពក្រីក្រ ។



## ២៤. តើមានបញ្ហាអ្វីខ្លះអាចកើតឡើងក្នុងដំណើរការបោះឆ្នោត ?

- មានការទិញទឹកចិត្តតាមរយៈ សំភារៈ និង លុយកាក់ ( ពិសេស ការទិញសន្លឹកឆ្នោតនៅយប់មុនថ្ងៃបោះឆ្នោតមួយថ្ងៃ) ។
- មានការបង្ខិតបង្ខំឱ្យប្រជាពលរដ្ឋធ្វើសម្បថ និងកត់លេខឯកសារបញ្ជាក់អត្តសញ្ញាណ
- មានការគំរាមកំហែង បំភិតបំភ័យ បង្ខិតបង្ខំលើប្រជាពលរដ្ឋ និងបេក្ខជន ឬសកម្មជនរបស់គណបក្សនយោបាយ ។
- ការរារាំង គំរាមកំហែងបេក្ខជនមិនឱ្យឈរឈ្មោះបោះឆ្នោត
- បង្កការលំបាក ឧបសគ្គដល់គណបក្សប្រឆាំង ឬគណបក្សតូចៗក្នុងការចុះបញ្ជីបេក្ខជន
- អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានបដិសេធមិនឱ្យចុះឈ្មោះបោះឆ្នោត
- ចុះឈ្មោះឱ្យអ្នកដែលគ្មានសិទ្ធិបោះឆ្នោត
- បាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ( នៅថ្ងៃបោះឆ្នោត)
- ក្នុងពេលយុទ្ធនាការឃោសនា មិនគោរពគោលការណ៍ស្មើភាព ( ឃោសនាមុនកាលកំណត់...) ។
- មានអំពើហិង្សា និងការសំលាប់ខាងនយោបាយ
- មិនធានានូវសុវត្ថិភាព សន្តិសុខ
- មិនធានានូវសេរីភាពក្នុងការបញ្ចេញមតិ
- អ្នកបោះឆ្នោតត្រូវបានបញ្ចុះបញ្ចូល ដើម្បីរារាំងមិនឱ្យទៅបោះឆ្នោត
- មានភាពយឺតយ៉ាវក្នុងដឹកជញ្ជូន និងផ្តល់សម្ភារៈបោះឆ្នោត
- មានភាពមិនប្រក្រតីក្នុងការដឹកជញ្ជូនហិបឆ្នោត
- មានភាពយឺតយ៉ាវក្នុងការរាប់សន្លឹកឆ្នោត
- ពេលរាប់សន្លឹកឆ្នោតមានការបន្លំ មានការរំខាន

- មានការរារាំងអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយមិនឱ្យចូលរួមសង្កេតការណ៍។
- អនុញ្ញាតិឱ្យអ្នកបោះឆ្នោតប្រើប្រាស់បណ្ណ័ព័ត៌មានអ្នកបោះឆ្នោតជំនួសឯកសារបញ្ជាក់អត្តសញ្ញាណនៅថ្ងៃបោះឆ្នោត។
- មានការយល់ច្រឡំជាមួយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បោះឆ្នោត ដែលធ្វើឱ្យអ្នកបោះឆ្នោតត្រូវបានគេបដិសេធ ឬត្រូវបានដេញឱ្យទៅយកឯកសារបញ្ជាក់អត្តសញ្ញាណ នាំឱ្យអ្នកបោះឆ្នោតមានការធុញទ្រាន់លែងមកបោះឆ្នោត។

# ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

## ២៥. តើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២នេះធ្វើឡើងក្នុងគោលបំណងអ្វី?

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតធ្វើឡើងដើម្បីសម្អាតបញ្ជីបោះឆ្នោត កែតម្រូវឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតថ្មី ដើម្បីបង្កើតបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំឱ្យកាន់តែមានបច្ចុប្បន្នភាព និងសុក្រឹតភាពសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ។

## ២៦. តើនរណាខ្លះដែលត្រូវទៅចុះឈ្មោះ និងនរណាខ្លះត្រូវទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត?

***អ្នកដែលត្រូវចុះឈ្មោះបោះឆ្នោត:***

- អ្នកមានសិទ្ធិបោះឆ្នោតទើបគ្រប់អាយុ១៨ឆ្នាំគិតដល់ថ្ងៃទី២៨ ខែកក្កដា

ឆ្នាំ២០១៣( អ្នកដែលកើតមុន ឬកើតត្រឹមថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៥) ។

- អ្នកដែលពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត
- អ្នកដែលទើបផ្លាស់ទីលំនៅចូលមកពីឃុំ សង្កាត់ផ្សេង ទោះបីធ្លាប់បានចុះឈ្មោះ ឬមិនធ្លាប់បានចុះឈ្មោះបោះឆ្នោតក៏ដោយ ។

ដើម្បីចុះឈ្មោះបោះឆ្នោត លោកអ្នកត្រូវទៅបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ដោយត្រូវយកទៅជាមួយនូវឯកសារដើម្បីបំពេញលក្ខខណ្ឌ ៤យ៉ាង គឺ÷ **អត្តសញ្ញាណ សញ្ជាតិ អាយុ និងទីលំនៅក្នុងឃុំ សង្កាត់** ។

***អ្នកដែលត្រូវពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ឬទៅពិនិត្យមើលឈ្មោះ***

- អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ឆ្នាំ២០១១

***ពេលទៅពិនិត្យមើលឈ្មោះ÷***

- *ឃើញឈ្មោះរបស់ខ្លួនត្រឹមត្រូវ:* ត្រូវកត់ចំណាំលេខរៀងឈ្មោះ លេខកូត និងទីតាំងការិយាល័យបោះឆ្នោត ។
- *ឃើញឈ្មោះ តែខុសអក្ខរាវិរុទ្ធ ឬទិន្នន័យមិនត្រឹមត្រូវ:* ត្រូវជួបស្មៀន ដើម្បីកែតម្រូវតាមឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលយកមកបង្ហាញ ។
- *ឃើញឈ្មោះ តែការិយាល័យបោះឆ្នោតនៅឆ្ងាយពីទីលំនៅលើស ពី ៥គ.ម :* ត្រូវជួបស្មៀន ដើម្បីសុំប្តូរការិយាល័យបោះឆ្នោត ។
- *មិនឃើញឈ្មោះ :* ត្រូវជួបស្មៀន ដើម្បីសុំឱ្យជួយរក បើពុំឃើញទើបសុំចុះឈ្មោះថ្មី ។
- *ឃើញឈ្មោះស្ទួន:* ត្រូវជួបស្មៀន ដើម្បីសុំលុបឈ្មោះស្ទួនលើសចេញ

ទុកតែឈ្មោះមួយគត់ ។

**២៧~ តើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២នេះធ្វើឡើងនៅពេលណា? កន្លែងណា?**

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើមពី**ថ្ងៃទី០១ ខែកញ្ញា** ដល់**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២** ។

ប្រជាពលរដ្ឋខ្មែរ ត្រូវទៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំង**នៅសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយក្នុងឃុំ សង្កាត់** ដើម្បីពិនិត្យបញ្ជីឈ្មោះ ឬសុំចុះឈ្មោះបោះឆ្នោត ។

ស្មៀនឃុំ សង្កាត់ត្រូវធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ។ ម៉ោងពេលធ្វើការត្រូវបានកំណត់:

- **ពេលព្រឹក:** ចាប់ពីម៉ោង **៧:០០** ដល់ម៉ោង **១១:៣០**នាទី
- **ពេលរសៀល:** ចាប់ពីម៉ោង **២:០០** រសៀល ដល់ម៉ោង **៥:៣០**នាទី ល្ងាច

*ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនេះ មានរយៈពេល* ***៤២ថ្ងៃ*** :

- **ពីថ្ងៃទី០១ -១៥ ខែកញ្ញា ឆ្នាំ២០១២:** នៅសាលាឃុំ សង្កាត់
- **ពីថ្ងៃទី១៦ ខែកញ្ញា ដល់ ០៦ តុលា ឆ្នាំ២០១២:** នៅតាមភូមិ
- **ពីថ្ងៃទី០៧ -១២ ខែតុលា ឆ្នាំ២០១២:** នៅសាលាឃុំ សង្កាត់

**២៨~ តើឯកសារអ្វីខ្លះដែលបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២នេះ?**

ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោតមានច្រើនប្រភេទ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋធម្មតា គួរយកឯកសារទៅជាមួយ **មួយ ឬច្រើន**ក្នុងចំណោមឯកសារដូចខាងក្រោមនេះ ÷

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ
- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- លិខិតបញ្ជាក់ទីលំនៅ (ទ.១០១៩)
- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត
- សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត
- ប័ណ្ណសំគាល់គ្រួសារ

# យុទ្ធនាការឃោសនាបោះឆ្នោត

## ២៩- តើការឃោសនាបោះឆ្នោតមានបំណងអ្វី?

ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍរាជធានី ខេត្ត និងប្រទេសជាតិជូនដល់អ្នកបោះឆ្នោត។



## ៣០. តើយុទ្ធនាការឃោសនាបោះឆ្នោតចាប់ផ្តើមនៅពេលណា និងបញ្ចប់នៅពេលណា?

- យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល **៣០ថ្ងៃ** គឺ ចាប់ពី**ថ្ងៃទី២៧ ខែមិថុនា** ដល់**ថ្ងៃទី២៦ ខែកក្កដា** ឆ្នាំ២០១៣ ហើយគ្រប់សកម្មភាពនៃការឃោសនាគឺត្រូវចប់**ម្ភៃបួន (២៤)ម៉ោងមុន**ថ្ងៃបោះឆ្នោត( **មួយ(០១)ថ្ងៃមុន**ថ្ងៃបោះឆ្នោត ហៅថា ***"ថ្ងៃស"***)។
- គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោងប្រាំមួយ(៦)ព្រឹក ដល់ម៉ោង ដប់ (១០)យប់ និងត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ដប់ (១០)យប់ ដល់ម៉ោង ប្រាំមួយ (៦)ព្រឹក។
- សកម្មភាពឃោសនាដោយឧបករណ៍បំពងសម្លេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២)ថ្ងៃត្រង់ ដល់ម៉ោងពីរ (២)រសៀល។

## ៣១. តើការឃោសនាបោះឆ្នោតធ្វើនៅកន្លែងណា?

ការឃោសនាបោះឆ្នោត ត្រូធ្វើឡើងនៅតាមរោងវីដេអូសាធារណៈ ឬទីសាធារណៈ។ ប្រជាពលរដ្ឋអាចសាកសួរព័ត៌មានពីគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) អំពីទីកន្លែង និងគណបក្សដែលធ្វើការឃោសនា។

## ៣២. តើសកម្មភាពអ្វីខ្លះដែលធ្វើឡើងក្នុងពេលឃោសនាបោះឆ្នោត ?

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

សកម្មភាពឃោសនារួមមាន÷

- ការជួបជុំជាសាធារណៈ

- ក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើងឬដោយយានជំនិះគ្រប់ប្រភេទ
- ការបញ្ចុះបញ្ចូលពីផ្ទះមួយទៅផ្ទះមួយ
- ការផ្សព្វផ្សាយតាមឧគ្ឃោសនស័ព្ទដើម្បីគាំទ្របេក្ខជនណាម្នាក់ ឬគោលនយោបាយគណបក្សនយោបាយណាមួយ ។
- ស្រែកជាពាក្យស្លោកខ្លីៗតាមឧបករណ៍បំពងសម្លេងឬតាមឧបករណ៍បញ្ចាំងរូបភាពដែលអាចឱ្យប្រជាពលរដ្ឋស្តាប់ និងមើលបាននូវសារនយោបាយ ។
- ផ្សព្វផ្សាយតាមរយៈការចាក់កាសែត្សវីដេអូ ឬវីស៊ីឌី ឬឌីវីឌី
- បិទផ្សាយនូវរូបភាពឃោសនា លើកបដា តំឡើងបន្ទះក្តារបិទប្រកាសផ្សាយ
- ការចែកចាយខិត្តប័ណ្ណគណបក្ស មួក សំលៀកបំពាក់ អាវយឺត ផ្លាកសញ្ញា ឬសម្ភារៈផ្សេងៗទៀត ។
- ការប្រគុំតន្ត្រីដោយដើរជាក្បួន ឬច្រៀងចំរៀងឃោសនា ឬការលេងភ្លេងឃោសនា ។
- ព្រឹត្តិការណ៍កីឡា ។ល ។

## ៣៣- តើមធ្យោបាយដឹកជញ្ជូនណាខ្លះត្រូវបានហាមឃាត់នៅពេលឃោសនាបោះឆ្នោត?

មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរដ្ឋដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញារាជការ រដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ។

## ៣៤- តើនរណាខ្លះអាចចូលរួម និងនរណាខ្លះមិនអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះបេក្ខជន ឬគណបក្សនយោបាយណាមួយ?

- ***អ្នកមានសិទ្ធិចូលរួមគាំទ្រក្នុងសកម្មភាពឃោសនាគ្រប់ម៉ោង:*** គឺប្រជាពលរដ្ឋ

ខ្មែរទាំងពីរ (០២) ភេទ។

■ ***អ្នកមិនមានសិទ្ធិចូលរួមសកម្មក្នុងការឃោសនាក្នុងអំឡុងម៉ោងធ្វើការ*** គឺមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ។ ប៉ុន្តែបន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ អ្នកទាំងនេះអាចចូលរួមក្នុងសកម្មភាពឃោសនាបោះឆ្នោតគាំទ្រចំពោះបេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ។

## ៣៥. តើបញ្ហាអ្វីខ្លះជាការរំលោភក្នុងពេលធ្វើការឃោសនាបោះឆ្នោតដែលយើងគួរកត់សម្គាល់ ?

♦ ធ្វើសកម្មភាពឃោសនារំលោភលើកាលបរិច្ឆេទ (មុនថ្ងៃទី១៨ ខែឧសភា និងក្រោយថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២)។

♦ អំពើហិង្សា ឬការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្ខំធ្វើសម្បថ ឬបង្ខំឱ្យផ្តិតមេដៃពីគណបក្សនយោបាយ អ្នកមានអំណាច កងកម្លាំងប្រដាប់អាវុធ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ។

♦ ការផ្តល់ប្រាក់កាស ឬសម្ភារៈក្នុងគោលបំណងទិញសន្លឹកឆ្នោត

♦ ប្រើសំដីប្រមាថមើលងាយអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជន។

♦ មានវត្តមានកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ចូលរួមគាំទ្រសកម្មភាពឃោសនាបោះឆ្នោតក្នុងម៉ោងធ្វើការ។

♦ ភាពលំអៀងលើការប្រើប្រាស់ទីសាធារណៈ

♦ អំពើបៀតបៀនរបស់គណបក្សនយោបាយ ឬបេក្ខជនទៅលើគណបក្ស

នយោបាយ ឬបេក្ខជនផ្សេងទៀត ។

♦ ការជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។ល។ និង ។ល។

## ៣៦. តើភារកិច្ច និងកាតព្វកិច្ចរបស់ប្រពន្ធ័ផ្សព្វផ្សាយ*រដ្ឋមានអ្វីខ្លះ?*

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មានដែលស្មើឡើងដោយគ.ជ.ប ដោយឥតគិតថ្លៃ ។

## ៣៧. តើលោក អ្នកត្រូវមានសកម្មភាពអ្វីខ្លះក្នុងពេលឃោសនាបោះឆ្នោត?

- ចូលរួមស្តាប់ការឃោសនារបស់បេក្ខជនតាមរយៈ ការប្រជុំ មីទ្ទិញ ការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ។
- មើល អានឯកសារឃោសនារបស់គណបក្ស ដូចជា ខិត្តប័ណ្ណ ផ្ទាំងរូបភាព ទូរទស្សន៍ និងឯកសារផ្សេងៗ ។
- លើកឡើងពីតំរូវការចាំបាច់ក្នុងឃុំ សង្កាត់របស់ខ្លួនទៅបេក្ខជន( ស្ត្រី-បុរស) និងគណបក្សនយោបាយនីមួយៗ ។
- សួរដេញដោលទៅបេក្ខជន និងគណបក្សនយោបាយនីមួយៗអំពីយុទ្ធសាស្ត្រធ្វើការងារតាមការសន្យាដោយជោគជ័យ ថាតើយុទ្ធសាស្ត្រទាំងនោះមានលក្ខណៈប្រាកដនិយម ឬច្បាស់លាស់អាចធ្វើបានដែរឬទេ? ឬគ្រាន់តែនិយាយក្នុងគោលបំណងទាក់ទាញសន្លឹកឆ្នោតពីអ្នកបោះឆ្នោតតែប៉ុណ្ណោះ? តើមានបានលើកឡើងអំពីការដោះស្រាយបញ្ហារបស់ស្ត្រីដែរឬទេ? តើមានគោលនយោបាយលើកស្ទួយស្ត្រីឱ្យក្លាយជាអ្នកដឹកនាំ សម្រេចចិត្តបានក៏រិតណា?
- ស្រាវជ្រាវ និងពិភាក្សារកព័ត៌មានបន្ថែមពី បេក្ខជន គណបក្សនយោបាយ អ្នកជិតខាង និងបងប្អូនក្នុងភូមិឃុំ ។

# នៅថ្ងៃបោះឆ្នោត

## ថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣




### ៣៨- តើថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ ធ្វើឡើង នៅថ្ងៃ ខែ ឆ្នាំណា?

ថ្ងៃបោះឆ្នោតត្រូវធ្វើឡើងតែមួយថ្ងៃគត់គឺ ***ថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ចាប់ពីម៉ោង ៧.០០ព្រឹក រហូតដល់ ម៉ោង ៣.០០រសៀល*** ។

### ៣៩- ទីកន្លែងបោះឆ្នោត

អ្នកបោះឆ្នោត ត្រូវទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលឈ្មោះរបស់ខ្លួនមាននៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនោះ (ទៅបោះឆ្នោតតាមលេខកូតការិយាល័យ និងលេខរៀងឈ្មោះរបស់ខ្លួនដែលបានកត់ត្រាទុក ឬមាននៅក្នុងប័ណ្ណព័ត៌មានអ្នកបោះឆ្នោត) ។

## ៤០. ដើម្បីបោះឆ្នោតបាន និងងាយស្រួល តើលោកអ្នកត្រូវធ្វើដូចម្តេច?

- ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ
- ត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ( ឈ្មោះ សញ្ជាតិ អាយុ)
- ទៅឱ្យទាន់ម៉ោងពី ម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៣:០០ រសៀល
- ស្គាល់លេខកូតការិយាល័យ ទីតាំងការិយាល័យបោះឆ្នោត និងលេខរៀងឈ្មោះរបស់ខ្លួន។
- មិនមានទឹកខ្មៅប្រឡាក់ម្រាមដៃ

## ៤១. តើឯកសារបញ្ជាក់អត្តសញ្ញាណអ្វីខ្លះ ដែលលោក អ្នកត្រូវយកទៅជាមួយនៅថ្ងៃបោះឆ្នោត?

នៅថ្ងៃបោះឆ្នោត លោក អ្នកត្រូវយកឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន និងត្រូវចងចាំនូវលេខកូតការិយាល័យ និងលេខរៀងឈ្មោះរបស់ខ្លួនដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

*លោក អ្នកត្រូវកាន់យកទៅជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ**ណាមួយ**ក្នុងចំណោមឯកសារដូចខាងក្រោម ÷*

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល នគរបាលជាតិ កងយោធពលខេមរភូមិន្ទ
- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- ឆាយាគណៈមហានិកាយ
- ប័ណ្ណសំគាល់ខ្លួនចេញដោយក្រសួងស្ថាបន័រដ្ឋ
- សង្ឃដីកា
- សៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួន
- ប័ណ្ណសម្គាល់គ្រួសារមានបិទរូបថតសាមីខ្លួន
- លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត

## ៤២. តើប័ណ្ណព័ត៌មានជាអ្វី?

ប័ណ្ណព័ត៌មានមិនមែនជាប័ណ្ណបោះឆ្នោតទេ និងមិនអាចប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួនបានឡើយ ។ វាគ្រាន់តែជាឯកសារជំនួយសម្រាប់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនឹងផ្តល់ព័ត៌មានអំពី "***កាលបរិច្ឆេទបោះឆ្នោត ទីតាំងការិយាល័យបោះឆ្នោត លេខកូដការិយាល័យបោះឆ្នោត ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងលេខរៀងឈ្មោះរបស់អ្នកបោះឆ្នោត***" ។

## ៤៣. តើអ្នកបោះឆ្នោតចាំបាច់យកប័ណ្ណព័ត៌មានទៅជាមួយសម្រាប់ការបោះឆ្នោតដែរឬទេ?

**អាចយកទៅក៏បាន មិនយកទៅក៏បាន!** ប៉ុន្តែលោក អ្នកត្រូវតែចងចាំអំពីទីតាំងការិយាល័យបោះឆ្នោត លេខកូដការិយាល័យបោះឆ្នោត និងលេខរៀងឈ្មោះរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការផ្ទៀងផ្ទាត់រកឈ្មោះរបស់លោក អ្នក។ លោក អ្នកត្រូវចងចាំថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គឺមិនមែនជាឯកសារបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក អ្នក សម្រាប់យកទៅបោះឆ្នោតឡើយ ។

## ៤៤. ករណី ៣ ដែលលោក អ្នកមិនអាចបោះឆ្នោតបាន

សូមចងចាំករណីទាំង ៣ នេះគឺ ÷

១- លោក អ្នកមិនបានចុះឈ្មោះបោះឆ្នោតជាមុន និង/ឬគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២- លោក អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយ ប៉ុន្តែលោក អ្នកមិនមានឯកសារបញ្ជាក់អំពីអត្តសញ្ញាណបង្ហាញមន្ត្រីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៣- លោក អ្នកមានស្នាមប្រឡាក់ទឹកខ្មៅលើម្រាមដៃ ។

**៤៥. តើអ្នកបោះឆ្នោតត្រូវមានតួនាទី ភារកិច្ច ដូចម្តេចខ្លះក្នុងថ្ងៃបោះឆ្នោត?**

- ត្រូវទៅបោះឆ្នោត

- ត្រូវបោះឆ្នោតតាមឆន្ទៈរបស់ខ្លួន ទោះបីបេក្ខជន ឬគណបក្សណាមួយបានឱ្យលុយ សម្ភារៈ ឱ្យធ្វើសម្បថ ឬបំភិតបំភ័យយ៉ាងណាក៏ដោយ។ ត្រូវចងចាំថា ការបោះឆ្នោតធ្វើឡើងដោយសម្ងាត់ គ្មាននរណាអាចដឹងបានទេ!

- ជួយពិនិត្យ និងផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតីក្នុងថ្ងៃបោះឆ្នោតទៅស្ថាប័នរៀបចំការបោះឆ្នោត អ្នកសង្កេតការណ៍ជាតិដូចជាខុមហ្វ្រែល (COMFREL ) និងអន្តរជាតិ ព្រមទាំងអ្នកសង្កេតការណ៍/និងឬភ្នាក់ងារគណបក្សនយោបាយ ។

**៤៦. នៅថ្ងៃបោះឆ្នោត បើលោក អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានឯកសារបញ្ជាក់អត្តសញ្ញាណ ប៉ុន្តែត្រូវគេរារាំងមិនឱ្យបោះឆ្នោត តើត្រូវធ្វើដូចម្តេច?**

- ករណីនេះ លោក អ្នកត្រូវ**រាយការណ៍ភ្លាម**ទៅប្រធានការិយាល័យបោះឆ្នោត ឬអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ។

- ករណីលោក អ្នកមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោត លោក អ្នកត្រូវធ្វើពាក្យបណ្តឹងលើទំរង់ ១២០២។

**៤៧. តើអ្វីខ្លះអាចធានាការសម្ងាត់នៃសន្លឹកឆ្នោត?(បើលោក អ្នកមានការជឿ ជាក់ សូមជួយផ្សព្វផ្សាយបន្ត)**

- ប្រជាពលរដ្ឋមានសិទ្ធិបដិសេធមិនឆ្លើយចំពោះសំណួរដែលចង់ដឹងថា ខ្លួនបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាមួយ ដោយមានសិទ្ធិរក្សាការសម្ងាត់នេះជាដាច់ខាត។

- ច្បាប់បោះឆ្នោតក៏បានធានាភាពសម្ងាត់នៃសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត

ពីជនណាដែលជជីកចង់ដឹង ឬគំរាមកំហែងអ្នកបោះឆ្នោត ឬលួងលោមសួរចង់ដឹង ឬប្រើប្រាស់មធ្យោបាយដើម្បីដឹងថា អ្នកបោះឆ្នោតបានបោះឆ្នោតគាំទ្រគណបក្ស ឬបេក្ខជនណាមួយនោះ ត្រូវមានទោសតាមច្បាប់បោះឆ្នោត ។

- អ្នកបោះឆ្នោតត្រូវមានការជឿជាក់ថា គ្មានជាដាច់ខាតនូវឧបករណ៍ទំនើបការថតរូបតាមកុំព្យូទ័រ ឬតាមផ្កាយរណប ឬ បច្ចេកទេសវិទ្យាសាស្ត្រណាដែលអាចមើលឃើញ អាចដឹងពីការសម្ងាត់នៃសន្លឹកឆ្នោតបានឡើយ ។
- សន្លឹកឆ្នោតដែលត្រូវបានប្រើប្រាស់គឺមិនមានការផ្ទៀងផ្ទាត់គល់បញ្ជីជាមួយនឹងសន្លឹកឆ្នោតទេ ។ សន្លឹកឆ្នោតមានលក្ខណៈ និងសណ្ឋានដូចគ្នាដោយគ្មានអ្វីជាសញ្ញាសំគាល់ឡើយ ។
- ប្រជាពលរដ្ឋគួរស្វែងយល់ពីការរក្សាការសម្ងាត់នៃសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតនៅក្នុងបន្ទប់សម្ងាត់ហើយបត់សន្លឹកឆ្នោតដោយមិនមានអ្នកណាឃើញទេ ។ បន្ទាប់មកអ្នកបោះឆ្នោតទំលាក់សន្លឹកឆ្នោតទៅក្នុងហិបឆ្នោត នៅពេលនោះសន្លឹកឆ្នោតនឹងលាយឡំគ្នានៅក្នុងហិបឆ្នោតដោយគ្មានអ្នកណាដឹងថាសន្លឹកឆ្នោតណាមួយជារបស់អ្នកណាឡើយ ។

**ដូចនេះ** សូមលោក អ្នកជឿជាក់ថា ការបោះឆ្នោតជាការសម្ងាត់ គ្មានអ្នកណាដឹងថា លោក អ្នកសំរេចចិត្តបោះឆ្នោតឱ្យគណបក្សណា ឬ បេក្ខជនណាមួយឡើយ ។ លោក អ្នកនឹងរក្សាការសម្ងាត់របស់ខ្លួនបានជារៀងរហូត ។

**៤៨. តើលោកអ្នកត្រូវបោះឆ្នោតតាមការសន្យាចំពោះគណបក្សដែលបានផ្តល់ប្រាក់កាស សម្ភារៈ ឬដឹកជញ្ជូនលោកអ្នកមកកាន់ស្ថានីយ៍បោះឆ្នោត ឬគំរាមកំហែងលោកអ្នកតាមពាក្យសំដី ឬអាកប្បកិរិយាដែរឬទេ?**

**មិនចាំបាច់បោះឆ្នោតឱ្យទេ** ! ការបោះឆ្នោត គឺជាការជ្រើសរើសដោយសេរីរបស់

លោកអ្នក ដើម្បីគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដែលលោកអ្នកពេញចិត្ត។ គ្មាននរណាម្នាក់អាចបង្ខំលោកអ្នកឱ្យបោះឆ្នោតឱ្យគណបក្សណាមួយបានឡើយ ។

ទោះបីលោកអ្នកធ្លាប់សន្យាដោយស្ម័គ្រចិត្ត ឬដោយបង្ខំ(ស្បថស្បែ)ជាមួយគណបក្សណាមួយ ឬបេក្ខជនណាមួយថានឹងបោះឆ្នោតឱ្យគេក៏ដោយ លោកអ្នកនៅតែមានសិទ្ធិសំរេចចិត្ត *ដោយសេរី តាមឆន្ទៈ និងការពេញចិត្តរបស់ខ្លួន* គឺមានតែលោកអ្នកម្នាក់គត់ដែលឈរក្នុងបន្ទប់សំងាត់បោះឆ្នោត ហើយគ្មាននរណាម្នាក់ដឹងថា លោកអ្នកបោះឆ្នោតឱ្យគណបក្សណាមួយឡើយ ។ សូមចងចាំថា *ការបោះឆ្នោតជាការសម្ងាត់* !

### ៤៩. តើលោក អ្នកនឹងមិនទៅបោះឆ្នោតមែនទេ នៅពេលដែលមិនឃើញមានអ្វីប្រែប្រួលជីវភាពក្រោយពេលបោះឆ្នោត ?

**សូមកុំអស់សង្ឃឹម!** សូមប្រែក្លាយការអស់សង្ឃឹមទៅជាការចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោត។ សូមលោក អ្នកជឿជាក់ថា គេអាចយកតំណក់ទឹកទៅបំបែកផ្ទាំងសិលាដ៏ធំមួយបាន ដូចនេះ ការទៅបោះឆ្នោតជ្រើសរើសតំណាងរបស់លោក អ្នកតាមការពេញចិត្តមានសារៈសំខាន់ណាស់ ដើម្បីជាកំលាំងចលករជំរុញឱ្យអ្នកជាប់ឆ្នោតទទួលខុសត្រូវ និងដោះស្រាយបញ្ហាទាំងឡាយក្នុងសង្គមជាបន្តបន្ទាប់ ដើម្បីអនាគតពួកយើង កូនចៅជំនាន់ក្រោយ និងប្រទេសជាតិយើងឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងមានការរីកចំរើន។

### ៥០. តើលោក អ្នកអាចនឹងខកខានការបោះឆ្នោតដែរឬទេ បើនៅថ្ងៃបោះឆ្នោតដល់ម៉ោង៣.០០រសៀលនៅហើយ លោក អ្នកនៅតែរង់ចាំក្នុងជួរដែលនៅខាងក្រៅការិយាល័យបោះឆ្នោត ?

**លោក អ្នកនៅតែអាចបោះឆ្នោតបានដដែល** ។ ម៉ោង៣.០០រសៀល មន្ត្រីទទួលបន្ទុកនៅការិយាល័យបោះឆ្នោតនឹងធ្វើការប្រមូលប័ណ្ណបញ្ជាក់អត្តសញ្ញាណរបស់ លោក

អ្នក ដែលនៅរង់ចាំក្នុងជួរទាំងអស់ គឺប្រមូលចាប់ពីជួរក្រោយមុន។ បន្ទាប់មក ពួកគេនឹងហៅឈ្មោះលោក អ្នកម្តងម្នាក់ៗឱ្យចូលទៅក្នុងការិយាល័យ ដើម្បីបោះឆ្នោតរហូតទាល់តែអស់ ។

## ៥១. តើលោក អ្នកអាចបោះឆ្នោតបានដែរឬទេ បើលោក អ្នកទៅដល់ការិយាល័យបោះឆ្នោតយឺត២ ឬ៣នាទី?

**ទេ ! លោក អ្នកមិនអាចបោះឆ្នោតបានទេ** ។ ជនណាក៏ដោយដែលមកដល់ការិយាល័យបោះឆ្នោតនៅក្រោយម៉ោង៣:00រសៀល ឬមិនបានឈរក្នុងជួរនោះ ពួកគេនឹងមិនមានសិទ្ធិក្នុងការគូសលើសន្លឹកឆ្នោត(បោះឆ្នោត) បានឡើយ ។

## ៥២. បើលោក អ្នកជាជនពិការ (ដែលគ្មានលទ្ធភាពគូសសន្លឹកឆ្នោតដោយខ្លួនឯងបាន) តើលោក អ្នកអាចបោះឆ្នោតបានយ៉ាងដូចម្តេច?

- **ពិតជាអាចបោះឆ្នោតបាន** ! លោក អ្នក មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនដែលទុកចិត្តបំផុតទៅជាមួយ ឬមានសិទ្ធិសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត ។
- នៅពេលដែលប្រធានការិយាល័យបោះឆ្នោត បានចាត់តាំងមនុស្សម្នាក់ឱ្យជួយ ឬនីតិជនទៅជាមួយលោក អ្នក។ ជននោះនឹងនាំលោក អ្នកទៅបន្ទប់សម្ងាត់ ហើយសួរលោក អ្នកតិចៗថា តើលោកអ្នកចង់បោះឱ្យគណបក្សណាមួយ? អ្នកជំនួយការនោះនឹងជួយលោក អ្នកគូសលើសន្លឹកឆ្នោតត្រង់ឈ្មោះគណបក្សនយោបាយដែលលោក អ្នកមានបំណងបោះឱ្យនោះ និងណែនាំលោក អ្នកឱ្យស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតផងដែរ ។
- ជំរើសដ៏ល្អបំផុតសម្រាប់លោក អ្នកជាជនពិការក្នុងការជ្រើសរើសអ្នកជំនួយពេលបោះឆ្នោត គឺគួរយកបងប្អូន មិត្តភក្តិ ឬអ្នកណាដែលលោក អ្នកទុកចិត្តបំផុត ។

## ៥៣. ក្នុងករណីអ្នកបោះឆ្នោតពិការម្រាមចង្អុលដៃស្តាំ តើអ្នកបោះឆ្នោតត្រូវ

**ប្រើម្រាមដៃណាដើម្បីជ្រលក់ទឹកខ្មៅ?**

ក្នុងករណីនេះអ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងតាមលំដាប់ដូចតទៅ : ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាការបាន។

**៥៤. តើលោក អ្នកអាចបោះឆ្នោតច្រើនដងបានដែរឬទេ?**

***អត់បានទេ!*** អ្នកបោះឆ្នោតទាំងអស់មានសិទ្ធិបោះឆ្នោតបានតែ *មួយដងគត់* ហើយបានតែ *មួយសន្លឹក*ដូចៗគ្នា។ ជនទាំងឡាយដែលបានបោះឆ្នោតហើយ មន្ត្រីការិយាល័យបោះឆ្នោតនឹងជ្រលក់ចង្អុលដៃស្តាំលោក អ្នក (កន្លែងផ្សេងទៀតបើជាជនពិការ) ក្នុងទឹកខ្មៅលុបលាងមិនជ្រះ ។ ប្រសិនបើមានស្នាមទឹកខ្មៅនេះនៅលើម្រាមដៃលោក អ្នក ប្រធានការិយាល័យនឹងប្រាប់ទៅភ្នាក់ងារគណបក្ស ឬអ្នកសង្កេតការណ៍ដើម្បីចំណាំ ហើយនឹងសួរនាំលោក អ្នកឱ្យពន្យល់អំពីមូលហេតុដែលមានស្នាមទឹកថ្នាំប្រឡាក់លើម្រាមដៃលោក អ្នក ។ ប្រសិនបើការពន្យល់របស់លោក អ្នកមិនសមហេតុផលទេនោះ ប្រធានការិយាល័យនឹងសន្និដ្ឋានថា លោក អ្នកព្យាយាមបោះឆ្នោត២ដង ។ ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់លោក អ្នកនឹងត្រូវដកហូត ហើយបញ្ជូនទៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ដើម្បីតាមដានបន្តទៀត។

**៥៥. តើលោក អ្នកត្រូវធ្វើដូចម្តេចនៅពេលដែលគូសច្រលំលើសន្លឹកឆ្នោត?**

- បើសិនលោក អ្នកគូសច្រលំលើសន្លឹកឆ្នោតដោយអចេតនាដែលមន្ត្រីការិយាល័យប្រគល់ឱ្យលោកអ្នកអាចសុំប្តូរសន្លឹកឆ្នោតផ្សេងទៀតពីប្រធានការិយាល័យបោះឆ្នោតបាន
- លោក អ្នកត្រូវបត់សន្លឹកឆ្នោតដែលខុសនោះឱ្យបាន២ដង ដើម្បីកុំឱ្យគេមើលឃើញ

រួចហុចឱ្យប្រធានការិយាល័យបោះឆ្នោត។

- ប្រធានការិយាល័យនឹងបង្គាប់ទៅអនុប្រធានឱ្យផ្តល់សន្លឹកឆ្នោតមួយផ្សេងទៀតឱ្យលោក អ្នក។

**សំគាល់:** លោក អ្នកអាចទទួលសន្លឹកឆ្នោតលើកទី២នេះបានតែម្តងគត់ ។

## ៥៦. បើក្នុងករណីមានធុរៈចាំបាច់ តើយើងអាចឱ្យអ្នកដទៃទៅបោះឆ្នោតជំនួសបានដែរឬទេ?

***អត់បានទេ !*** លោក អ្នកមិនអាចឱ្យអ្នកដទៃក្រៅពីខ្លួនយើងទៅបោះឆ្នោតជំនួសបានឡើយ។ អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ក្នុងមួយអាណត្តិ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់។ លោក អ្នកចាំបាច់ណាស់ត្រូវឆ្លៀតពេលទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ព្រោះថាការបោះឆ្នោត គឺជាជោគវាសនារបស់ភូមិ ឃុំ មណ្ឌល លោក អ្នកទាំងមូល ហើយត្រូវបានគេធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង។

## ៥៧. ចំពោះស្ត្រីមេផ្ទះដែលធ្វើការមមាញឹកនៅក្នុងផ្ទះ ហេតុអ្វីត្រូវខ្វល់ខ្វាយអំពីការបោះឆ្នោតនោះ?

**ត្រូវតែចូលរួមក្នុងការបោះឆ្នោត !** បងប្អូននារី និងស្ត្រីមេផ្ទះ គួរចាប់អារម្មណ៍ថាយើងក៏ជាសមាជិកម្នាក់ក្នុងសង្គមជាតិដែរ។ ដូច្នេះយើងត្រូវមានតួនាទីយ៉ាងសំខាន់ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ ដើម្បីអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែប្រសើរឡើង។ ដូចនេះ ទោះបីជាបងប្អូននារី និងស្ត្រីមេផ្ទះមានការមមាញឹកច្រើននឹងកិច្ចការផ្ទះយ៉ាងណាក៏ដោយ សូមបងប្អូនឆ្លៀតពេលទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា ព្រោះការបោះឆ្នោតគឺមានរយៈពេលតែមួយថ្ងៃគត់ យើងមិនត្រូវឱ្យឱកាសដ៏ល្អនេះកន្លងហួសទេ ព្រោះសន្លឹកឆ្នោតរបស់លោកស្រី នាងកញ្ញា*១សន្លឹកមានតម្លៃណាស់*សំរាប់អនាគតពួក យើងកូនចៅជំនាន់ក្រោយ និងអនាគតប្រទេសជាតិ។

**៥៨. បើលោក អ្នកជាជាងជួសជុលគ្រឿងម៉ាស៊ីនយន្តហោះ រថយន្ត ម៉ូតូ តើត្រូវលាងសំអាតម្រាមដៃរបស់ខ្លួនឬទេមុនពេលទៅបោះឆ្នោត?**

***ត្រូវតែលាងដៃ (ម្រាមដៃស្តាំ-ឆ្វេង)ឱ្យបានស្អាត!*** ដើម្បីងាយស្រួលបោះឆ្នោត និងចំណេញពេលវេលា។ ព្រោះថា បើម្រាមដៃលោក អ្នកមានប្រឡាក់ប្រេងម៉ាស៊ីនដែលមាន**ពណ៌ក្រម៉ៅស្រដៀងនឹងស្នាមទឹកខ្មៅ**សម្រាប់ឱ្យអ្នកបោះឆ្នោតជ្រលក់ចង្អុលដៃនោះ ប្រធានការិយាល័យបោះឆ្នោត មន្ត្រីផ្សេងៗទៀត ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិនឹងចាប់ផ្តើមសង្ស័យមកលើលោក អ្នក ហើយប្រធានការិយាល័យបោះឆ្នោតនឹងសួរនាំលោក អ្នកឱ្យពន្យល់អំពីមូលហេតុដែលមានស្នាមថ្នាំខ្មៅប្រឡាក់លើម្រាមដៃលោក អ្នក។ បើការពន្យល់របស់លោក អ្នកសមហេតុផល ប្រធានការិយាល័យបោះឆ្នោតនឹងអនុញ្ញាតឱ្យលោក អ្នកបោះឆ្នោត ប៉ុន្តែបើមិនសមហេតុផលទេ លោក អ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។ ដូច្នេះ លោក អ្នកត្រូវតែលាងសំអាតម្រាមដៃឱ្យបានស្អាតនៅមុនពេលចេញទៅបោះឆ្នោត។

# ការរាប់សន្លឹកឆ្នោត

**៥៩. តើការរាប់សន្លឹកឆ្នោតធ្វើឡើងនៅថ្ងៃណា? ពេលណា? កន្លែងណា?**

- ការរាប់សន្លឹកឆ្នោតធ្វើនៅ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ បន្ទាប់ពីបិទការបោះឆ្នោត។
- ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតតែម្តង (ការិយាល័យបោះឆ្នោតនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត) បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណី

*ប្រធានស័ក្តិ ឬអសន្តិសុខ* ហើយដែលគ.ជ.បសម្រេចឱ្យគឃ/សប ចាត់ចែងរាប់សន្លឹកឆ្នោតនៅទីស្នាក់ការគឃ/សប ឬនៅកន្លែងណាមួយដែលមាន សុវត្ថិភាព ។

**៦០. តើគេរាប់សន្លឹកឆ្នោតដែលមានតម្លាភាព ត្រូវធ្វើយ៉ាងដូចម្តេច?**

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយដែលអាចឮ និងមើលឃើញច្បាស់នូវគំនូសនៃការបោះឆ្នោតទាំងអស់ ដោយមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឯករាជ្យជាអ្នកតាមដាន និងផ្ទៀងផ្ទាត់ ។

**៦១. តើនរណាជាអ្នករាប់ និងទទួលខុសត្រូវលើសន្លឹកឆ្នោតនៅពេលរាប់?**

គឺមន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ក្លាយជាមន្ត្រីរាប់សន្លឹកឆ្នោត ដែលជាអ្នកទទួលខុសត្រូវក្នុងការិយាល័យរាប់សន្លឹកឆ្នោតរបស់ខ្លួន ។

**៦២. តើសន្លឹកឆ្នោតប្រភេទណាខ្លះដែលមិនអាចយកជាការបាន ?**

សន្លឹកឆ្នោតដែលត្រូវទុកជាមោឃៈ ឬមិនបានការ ÷

- ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ
- ពុំមែនជាសន្លឹកឆ្នោតដែលផ្តល់ឱ្យដោយការិយាល័យបោះឆ្នោត ឬ
- ដែលគ្មានគូស ឬមានគំនូស តែគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតពុំអាចសន្និដ្ឋានបានថា លោក អ្នកបោះឱ្យគណបក្សនយោបាយណាមួយ ឬ
- គូសឱ្យបញ្ជីបេក្ខជនលើសពីមួយ ឬ
- មានសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ
- ដែលមានរហែក ឬខូច ឬ
- ដែលគ្មានត្រាសម្ងាត់ជាផ្លូវការ ។

# ទោសប្បញ្ញត្តិ និងបណ្តឹង

**៦៣. តើសកម្មភាពខុសច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់គ.ជ.ប មានអ្វីខ្លះ?(តើសកម្មភាពខុសច្បាប់ណាខ្លះដែលចាត់ទុកថាបំពានច្បាប់បោះឆ្នោត ឬជាបទល្មើសបោះឆ្នោត?)**

សកម្មភាពខុសច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់គ.ជ.ប រួមមាន ÷

- ទិញសន្លឹកឆ្នោតដោយប្រាក់កាស ឬសម្ភារៈ

- ការគំរាមកំហែង ការលួងលោម ឬសួរដេញដោលពីគណបក្សដែលប្រជាពលរដ្ឋបោះឆ្នោតឱ្យ ។

- បង្ខំឱ្យធ្វើសម្បថបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្ត ។

- ប្រើកំលាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន

- លំអៀង និងមិនស្មោះត្រង់ក្នុងការអនុវត្តអំណាច មុខងារ និងភារកិច្ច

- យកអាវុធជាតិផ្ទុះដោយគ្មានការអនុញ្ញាតចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

- មានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់រហែក ឬរបូតសោឃ្លុំ ...

- បន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើល្បិចដើម្បីលួចបន្លំលទ្ធផលនៃការបោះឆ្នោត

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

## ៦៤. តើទណ្ឌកម្មចំពោះបទល្មើសនឹងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់គ.ជ.បមានដូចម្តេចខ្លះ?

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ទោសប្បញ្ញត្តិនៃច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់គ.ជ.ប ដែលនឹងអនុវត្តចំពោះបទល្មើសទាក់ទងនឹងការបោះឆ្នោតទៅតាមករណីនីមួយៗ មានក៏រិតដូចខាងក្រោម :

- ការស្តីបន្ទោស
- ការព្រមាន
- ការដាក់វិន័យរដ្ឋបាល
- ការព្យួរការងារ
- ការដាក់ឱ្យទំនេរគ្មានបៀវត្សរ៍

- ការបណ្តេញចេញពីការងារ
- ការដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត ។
- ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត
- ការលុបបេក្ខភាពរបស់សាមីខ្លួន ឬការលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្ស ។
- ការពិន័យជាប្រាក់ដែលមានចំនួនយ៉ាងតិចចន្លោះពីប្រាំលាន( ៥.000.000 ) រៀល រហូតដល់ ហាសិបលាន (៥0.000.000)រៀល ទៅតាមករណីនីមួយៗ ។ល ។

## ៦៥. តើប្រជាពលរដ្ឋមានសិទ្ធិប្តឹងទៅខាងណា នៅពេលបានឃើញជនណាមួយប្រព្រឹត្តិល្មើសច្បាប់បោះឆ្នោត ?

### ក - ជនល្មើសដែលមិនមែនជាមន្ត្រីបោះឆ្នោត

ជនគ្រប់រូប តំណាង ឬគណបក្សនយោបាយដែលមានប្រយោជន៍ (ម្ចាស់បណ្តឹង) ត្រូវប្តឹងទៅអាជ្ញាធររៀបចំការបោះឆ្នោតមានសមត្ថកិច្ចតាមឋានានុក្រមតាមលំដាប់ពីទាបទៅខ្ពស់មានជាអាទិ៍ **គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត** (គកប/គករ) **គណៈកម្មការឃុំសង្កាត់រៀបចំបោះឆ្នោត**(គឃ/សប) **គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត**(គធ/ខប) **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប) **ក្រុមប្រឹក្សាធម្មនុញ្ញ** និង**ស្ថាប័នតុលាការ** ។

- ***បណ្តឹងនាដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតៈ*** ក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរបំផុត បន្ទាប់ពីបដិសេធដោយស្មៀន ម្ចាស់បណ្តឹងត្រូវប្តឹងទៅកបឃ/ស ។ ប្រសិនបើមិនសុខចិត្តក្នុងរយៈពេល ៥ថ្ងៃ

យ៉ាងយូរបំផុតបន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ គាត់អាចប្ដឹងបន្តទៅ គ.ជ.ប។ បើនៅតែមិនយល់ព្រមទៀត ក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរបំផុត គាត់អាចប្ដឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។

**ម្ចាស់បណ្ដឹង ⇨ គបឃ/ស ⇨ គ.ជ.ប ⇨ទៅក្រុមប្រឹក្សាធម្មនុញ្ញ**

- ***បណ្ដឹងនាដំណាក់កាលនៃការបិទផ្សាយបញ្ជីដំបូង:*** មានយន្តការដូចការប្ដឹងនាដំណាក់កាលខាងលើនេះដែរ ខុសប្លែកតែរយៈពេលនៃការដាក់ពាក្យបណ្ដឹងនីមួយៗប៉ុណ្ណោះ ដោយត្រូវកំណត់មកត្រឹម ៥ថ្ងៃ យ៉ាងយូរបំផុតវិញ
- ***បណ្ដឹងនាដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ:*** បេក្ខជនឬគណបក្សនយោបាយ( ម្ចាស់បណ្ដឹង) ដែលត្រូវបានបដិសេធដោយ គ.ជ.ប ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរបំផុត ៥ថ្ងៃ។

**ម្ចាស់បណ្ដឹង ⇨ ទៅក្រុមប្រឹក្សាធម្មនុញ្ញ**

- ***បណ្ដឹងនាដំណាក់កាលឃោសនាបោះឆ្នោត:*** ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ ម្ចាស់បណ្ដឹងត្រូវប្ដឹងទៅគឃ/សប។ ករណីមិនសុខចិត្តក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរបំផុតបន្ទាប់ពីថ្ងៃសំរេចមិនសះជានៃកំណត់ហេតុផ្សះផ្សា ម្ចាស់បណ្ដឹងអាចប្ដឹងបន្តទៅគធ/ខប។ បើនៅតែមិនសុខចិត្តក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានសេចក្ដីសំរេច របស់ គធ/ខប ម្ចាស់បណ្ដឹងអាចប្ដឹងទៀតទៅគ.ជ.ប។ បើនៅតែមិនសុខចិត្ត

ទៀត ក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរបន្ទាប់ពីទទួលបានសេចក្ដីសំរេចរបស់ គ.ជ.ប ម្ចាស់បណ្ដឹងអាចប្ដឹងទៀតទៅក្រុមប្រឹក្សាធម្មនុញ្ញ។

**ម្ចាស់បណ្ដឹង → គយ/សប → គធ/ឧប → គ.ជ.ប → ក្រុមប្រឹក្សាធម្មនុញ្ញ**

- ***បណ្ដឹងនាដំណាក់កាលថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតៈ*** ម្ចាស់បណ្ដឹងត្រូវប្ដឹងផ្ទាល់មាត់ភ្លាមទៅប្រធានគកប/គករ។ បើមិនសុខចិត្ត ម្ចាស់បណ្ដឹងត្រូវប្ដឹងតាមទម្រង់១២០២ ទៅគយ/សបយ៉ាងយូរបំផុតត្រឹម ម៉ោង ១១:៣០ នាទីនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត (ត្រឹមម៉ោង១១:៣០នាទីនៃថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២)។ ករណីមិនសុខចិត្ត ក្នុងរយៈពេល២ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្ដីសំរេច ម្ចាស់បណ្ដឹងអាចប្ដឹងបន្តទៅគធ/ឧប។ បើនៅតែមិនសុខចិត្ត ក្នុងរយៈពេល២ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃចេញសេចក្ដីសំរេច ម្ចាស់បណ្ដឹងអាចប្ដឹងទៀតទៅគ.ជ.ប។

**ម្ចាស់បណ្ដឹង → គកប/គករ → គយ/សប → គធ/ឧប → គ.ជ.ប**

- បណ្ដឹងនាដំណាក់កាលនៃការប្រកាសលទ្ធផលបណ្ដោះអាសន្នៈ ករណីនេះបន្ទាប់ពីប្រកាសលទ្ធផលបណ្ដោះអាសន្នក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ ម្ចាស់បណ្ដឹងអាចប្ដឹងទៅគ.ជ.ប។ បើមិនសុខចិត្ត អាចប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល៧២ម៉ោងយ៉ាងយូរ ឬអាចប្ដឹងបដិសេធដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញតែម្ដងក៏បាន។

**ម្ចាស់បណ្ដឹង → គ.ជ.ប → ក្រុមប្រឹក្សាធម្មនុញ្ញ**

**ម្ចាស់បណ្ដឹង → ក្រុមប្រឹក្សាធម្មនុញ្ញ**

**៩. ជនល្មើសដែលជាមន្ត្រី ឬសមាជិករបស់អាជ្ញាធររៀបចំការបោះឆ្នោត**

ជនណាក៏ដោយមានសិទ្ធិប្ដឹងនូវកំហុសរបស់មន្ត្រីរៀបចំការបោះឆ្នោតនៅ ចំពោះមុខអាជ្ញាធររៀបចំការបោះឆ្នោត ***ថ្នាក់លើមួយថ្នាក់*** (ឧ: បើឃើញមន្ត្រីការិយាល័យបោះឆ្នោត ឬរាប់សន្លឹកឆ្នោតធ្វើខុសត្រូវប្ដឹងទៅគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)។ បើគឃ/សបធ្វើខុសត្រូវប្ដឹងទៅគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត(គធ/ខប)។ បើគធ/ខប ធ្វើខុសត្រូវប្ដឹងទៅ គ.ជ.ប។ បើមន្ត្រីនៅទីស្ដីការ គ.ជ.បធ្វើខុសត្រូវប្ដឹងទៅប្រធានគ.ជ.ប។ បើគ.ជ.បធ្វើខុសត្រូវប្ដឹងទៅរដ្ឋសភា កំណត់រយៈពេល៣ថ្ងៃយ៉ាងយូរបន្ទាប់ពីពេលកើតហេតុ លើកលែងតែកាលបរិច្ឆេទកំណត់ផ្សេងពីនេះក្នុងច្បាប់បោះឆ្នោត។

# ផ្នែកទី៤

# យេនឌ័រ និងក្ដីតាជាតំណាងអ្នកបោះឆ្នោត

## ៦៦. តើយេនឌ័រមានន័យយ៉ាងដូចម្ដេច?

សំដៅទៅលើភាពខុសគ្នា រវាងបុរស និងស្ត្រីដែលកំណត់ដោយសង្គម ហើយដែលគេបានរៀនសូត្រ និងមានការប្រែប្រួលពីពេលមួយទៅពេលមួយ។ យេនឌ័រមានការផ្លាស់ប្ដូរយ៉ាងទូលំទូលាយរវាងតួនាទីបុរស និងស្ត្រីទៅតាមវប្បធម៌នៅក្នុងសង្គម និងរវាងវប្បធម៌មួយទៅវប្បធម៌មួយទៀត។

***"យេនឌ័រ"*** គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ច សង្គមក្នុងការធ្វើវិភាគលើតួនាទីទទួលខុសត្រូវ ឧបសគ្គ និងតម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទទាំងអស់។ ដោយសារ ***"យេនឌ័រ"*** ត្រូវបានបង្កើតឡើងដោយសង្គម ទើបការកំណត់អំពីតួនាទី តម្រូវការ

អាទិភាព និងសកម្មភាពរបស់ស្ត្រីមានទំនាក់ទំនងនឹងបរិបទជាក់ស្តែងនៃវប្បធម៌ សាសនា និងសេដ្ឋកិច្ចសង្គម ។

## ៦៧- តើយេនឌ័រមានសារៈសំខាន់អ្វីខ្លះ?

ស្ត្រី និងបុរសជាដៃគូនឹងគ្នាក្នុងការអភិវឌ្ឍប្រទេសជាតិ ។ មាន**សមភាពយេនឌ័រ** គឺមានន័យថា ការចូលរួមរបស់ស្ត្រី និងបុរសមានភាពស្មើគ្នាទាំងការងារក្នុងសង្គម និងនៅផ្ទះ ។ មាន**សមធម៌យេនឌ័រ**មានន័យថា ការប្រព្រឹត្តចំពោះភេទទាំងពីរគឺដូចគ្នា ។ ក្នុងន័យនេះ គឺសំដៅទៅលើការឱ្យតំលៃលើគុណភាពការងារ ការផ្តល់ឱកាស និងការទទួលផលប្រយោជន៍ ។

នៅពេលដែលគោលការណ៍ទាំងពីរនេះត្រូវបានគេគោរព និងអនុវត្តដោយពេញលេញនោះ ការរើសអើងទៅលើស្ត្រីត្រូវបានលុបបំបាត់ចោល ។ ជាលទ្ធផល អំពើហិង្សាដែលកើតមានទៅលើស្ត្រីអាចត្រូវបានដោះស្រាយ ឬ កាត់បន្ថយ ពោលគឺមានការគោរពសិទ្ធិគ្នាទៅវិញទៅមករវាងបុរស និងស្ត្រី នាំឱ្យកាត់បន្ថយនូវបញ្ហាសង្គម ។

## ៦៨- តើប្រព័ន្ធកូតាយេនឌ័រសំរាប់តំណាងអ្នកបោះឆ្នោតមានន័យដូចម្តេច?

គំនិតសំខាន់នៃប្រពន្ធ័កូតា គឺដើម្បីជ្រើសរើសស្ត្រីឱ្យកាន់តំណែងនយោបាយ និងដើម្បីធានាថាស្ត្រីមិនមែនជាអ្នកដែលត្រូវបានគេជ្រើសរើសតិចតួចនៅក្នុងជីវិតនយោបាយ ។

ប្រព័ន្ធកូតាយេនឌ័រ សំដៅធានាឱ្យបានថា ស្ត្រី ឬបុរស (ជាពិសេសស្ត្រី) ចូលរួមក្នុងគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច សង្គម ក៏វិត ៥០% ទល់នឹង ៥០% ទោះបីនៅប្រទេសមួយចំនួន កូតានេះត្រូវបានកំណត់ត្រឹម ៣០% ឬ ៤០%ក៏ដោយ ។

**ការអនុវត្តប្រពន្ធ័កូតាមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ !**

**ការវិវត្តថ្មីមួយទៀត គឺ "ក្លូតាទ្វេ"**



***ក្លូតាទ្វេ*** ត្រូវបានប្រើនៅក្នុងប្រពន្ធ័កូតា គឺមិនត្រឹមតែកំណត់ភាគរយដាក់លាក់មួយរបស់ស្ត្រីនៅក្នុងបញ្ជីឈរឈ្មោះបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងបង្ការឱ្យបានថា បេក្ខនារីមិនត្រូវបានគេដាក់ឈ្មោះនៅខាងក្រោមៗនៃបញ្ជីបេក្ខជន។ មានន័យថា បេក្ខនារីត្រូវបានគេដាក់ឈ្មោះនៅខាងលើនៃបញ្ជីបេក្ខជន ឬក៏ត្រូវបានដាក់ឈ្មោះឆ្លាស់គ្នារវាងបេក្ខជន និងបេក្ខនារីនៅខាងលើនៃបញ្ជីបេក្ខជនឈរឈ្មោះយ៉ាងហោច ៣០%ទៅ៤០% ។

## ៦៩. តើប្រព័ន្ធក្លូតាយេនឌ័រមានសារៈសំខាន់អ្វីខ្លះ?

**មានសារៈសំខាន់ណាស់!** ព្រោះវាជួយឱ្យមានការលើកទឹកចិត្តដល់ស្ត្រីក្នុងការចូលរួមក្នុងកិច្ចការសង្គម ក៏ដូចជានយោបាយ ហើយមានប្រយោជន៏ថែមទៀតសំរាប់ប្រទេសដែលមានវិសមភាពយេនឌ័រដូចជាប្រទេសកម្ពុជា ពីព្រោះប្រព័ន្ធនេះជួយជំរុញឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ដល់ស្ត្រី និងជួយស្ត្រីឱ្យមានឱកាសក្លាយជាអ្នកដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

- ការប្រើប្រាស់ប្រព័ន្ធកូតា គឺកាត់បន្ថយនូវគម្លាតរវាងបុរស និងស្ត្រីក្នុងការធ្វើសេចក្តីសំរេចចិត្ត ។
- ប្រព័ន្ធកូតានេះ គឺជាគន្លឹះសំរាប់ជំរុញ និងលើកទឹកចិត្តឱ្យស្ត្រីបានបង្ហាញនូវសក្តានុពលរបស់ខ្លួនថាគាត់ក៏ជាធនធានមួយដ៏មានសារៈសំខាន់ ដែលសង្គមជាតិត្រូវការចាំបាច់ដែរ។
- កូតានេះ គឺជាការលើកទឹកចិត្តឱ្យស្ត្រីបានចូលរួមដោយពេញលេញ ដោយស្មើភាព

និងដោយសកម្មក្នុងការងារនយោបាយ ក៏ដូចជាការងារសាធារណៈ ដែលនឹងនាំមកនូវការផ្លាស់ប្តូរទម្លាប់នៃការអនុវត្តនយោបាយដើម្បីដោះស្រាយ និងសេចក្តីត្រូវការរបស់ស្ត្រី និងកុមារ ។ ការបង្កើនឱ្យមាននូវតម្លាភាព និងការទទួលខុសត្រូវរួមបញ្ចូលទាំងការឆ្លើយតបយ៉ាងរហ័សទៅនឹងសេចក្តីត្រូវការ និងការទាមទាររបស់ប្រជាពលរដ្ឋ។ មានសារៈសំខាន់ណាស់ក្នុងការពង្រឹងអភិបាលកិច្ចល្អ ដែលទាំងនេះគឺជាលក្ខខណ្ឌចាំបាច់សំរាប់ពន្លឿនសមភាព និងសមធមិយេនឌ័រនៅកម្ពុជា ។

**៧០៖ តើគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ គួរមានចំណុចសំខាន់អ្វីខ្លះ?**

គោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់គួរមានចំណុចសំខាន់ៗដូចខាងក្រោម ÷

- ត្រូវមានតម្លាភាពលើគ្រប់កិច្ចការ
- ត្រូវមានសមធមិ និងសមភាពយេនឌ័រពិតប្រាកដ
- ត្រូវមានគណនេយ្យភាព (ការទទួលខុសត្រូវខ្ពស់)
- មានការត្រួតពិនិត្យនិងតាមដានការចូលរួមអនុវត្តការងាររបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងស្ត្រី និងបុរស ។
- ផ្តល់ឱកាសដល់ស្ត្រីបានចូលរួមគ្រប់សកម្មភាព
- បង្កើនសមត្ថភាពដល់ស្ត្រីជាពិសេស

**៧១៖ តើគោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រសម្រាប់គណបក្សនយោបាយ គួរមានចំណុចសំខាន់អ្វីខ្លះ?**

គោលនយោបាយ ឬផែនការសកម្មភាពយេនឌ័រសម្រាប់គណបក្សនយោបាយ

គួរមានចំណុចសំខាន់ៗដូចខាងក្រោម ÷

- យុត្តិធម៌សម្រាប់ស្ត្រីលើគ្រប់កិច្ចការ
- ផែនការសកម្មភាពក្នុងការបណ្តុះបណ្តាលស្ត្រី
- កំណត់ចំនួនកូតាតាមស្ថាប័ននានារបស់គណបក្ស
- ការពារ និងលើកស្ទួយដើម្បីពង្រីកការចូលរួមរបស់ស្ត្រី
- ផ្តល់ឱកាសឱ្យស្ត្រីបានក្លាយជាថ្នាក់ដឹកនាំឱ្យបានច្រើន
- ត្រូវពិនិត្យមើលរចនាសម្ព័ន្ធរបស់គណបក្សនីមួយៗ ហើយបញ្ចូលស្ត្រីជាអ្នកដឹកនាំក្នុងគណបក្សចាប់ពីថ្នាក់លើរហូតដល់ថ្នាក់មូលដ្ឋាន។

## ៧២. ហេតុអ្វីបានជាស្ត្រីត្រូវចូលរួមក្នុងឆាកនយោបាយ និងជាអ្នកដឹកនាំនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ?

- ដើម្បីឱ្យបញ្ហាស្ត្រី និងកុមារត្រូវបានយកចិត្តទុកដាក់ដោះស្រាយ
- ដើម្បីឱ្យស្ត្រីអាចអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងដំណើរការអភិវឌ្ឍន៍សង្គមជាតិ
- ស្ត្រីគ្រប់រូបមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ
- ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមក្នុងតួនាទីធ្វើសេចក្តីសំរេចចិត្ត
- ដើម្បីចូលរួមក្នុងដំណើរការវិមជ្ឈការ និងប្រជាធិបតេយ្យ
- ស្ត្រីគឺជាភ្នាក់ងារដែលធ្វើឱ្យមានការប្រែប្រួលនៅក្នុងសង្គម និងធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពស្ត្រី។
- កាលណាមានស្ត្រីចូលរួមកាន់តែច្រើននៅក្នុងវិស័យនយោបាយ ពេលនោះស្ត្រីខ្លួនឯងនឹងមានទឹកចិត្តចូលរួមកាន់តែខ្លាំង និងជាគំរូសម្រាប់ក្មេងស្រីជំនាន់ក្រោយ។
- ដើម្បីលើកស្ទួយតំលៃស្ត្រី និងសមភាពយេនឌ័រ
- ដើម្បីបង្ហាញថាស្ត្រីក៏មានសមត្ថភាពដូចបុរសដែរ

- ដើម្បីកាត់បន្ថយទស្សនៈ ***"ស្ត្រីជាភេទទន់ខ្សោយ"***
- ដើម្បីការពារសិទ្ធិស្ត្រី និងអភិវឌ្ឍស្ត្រី ។
- ការពារផលប្រយោជន៏ស្ត្រីទាំងមូល
- ស្ត្រី និងបុរសមានសេចក្តីត្រូវការដោយឡែកៗពីគ្នា
- បើស្ត្រីមិនបានចូលរួម ស្ត្រីនៅតែមិនមានឱកាស ខ្វះបទពិសោធ និងមិនបាន បង្កើនសមត្ថភាព ។
- ស្ត្រីត្រូវមានការយល់ដឹងពីនយោបាយ ដើម្បីអាចជួយតំរង់ទិសរួមគ្នា
- ស្ត្រីចូលរួមផ្តល់មតិ បំពេញភាពខ្វះចន្លោះ
- ដើម្បីកែទំរង់នយោបាយ និងរចនាសម្ពន្ធ័ច្បាប់របស់ជាតិ ដោយសន្តិវិធី

**៧៣~ តើឧបសគ្គអ្វីខ្លះដែលរារាំងស្ត្រីមិនឱ្យចូលរួមក្នុងវិស័យនយោបាយ?**

- ខ្វះគោលនយោបាយសមធមមិជាលាយលក្ខណ៏អក្សរក្នុងការលើកកម្ពស់ និងផ្តល់ ឱកាសដល់ស្ត្រីនៅក្នុងគណបក្សនយោបាយ និងច្បាប់បោះឆ្នោត ។
- ខ្វះយន្តការពិសេសដើម្បីគាំទ្រ និងផ្តល់ឱកាសដែលជាវិធានការសម្រាប់ស្ត្រីចូល រួមលើគ្រប់វិស័យស្របតាមអនុសញ្ញាអន្តរជាតិស៊ី-ដ (CEDAW) ។
- ដោយសារទំនៀមទម្លាប់អភិរក្សនិយម និងវប្បធមិដែលត្រូវបានគេសន្មត់ និងឱ្យ តម្លៃស្ត្រីទាបជាងបុរសនៅគ្រប់វិស័យនៅក្នុងសង្គម ។
- ខ្វះការផ្តល់ឱកាស និងការគាំទ្រពីបុរស និងសង្គម
- ខ្វះការលើកទឹកចិត្តពីគ្រួសារ និងស្វាមី
- ឋានៈទាបក្នុងយន្តការធ្វើសេចក្តីសំរេចចិត្ត
- ការរើសអើងរវាងតួនាទីបុរស-ស្ត្រីក្នុងវិស័យការងារ
- ខ្វះចំណេះដឹង ជំនាញ និងបទពិសោធ

- ខ្វះជំនឿលើខ្លួនឯង
- ជីវភាពគ្រួសារ ភាពក្រីក្រ

## ៧៤. តើការផ្តល់អំណាចដល់ស្ត្រីមានន័យដូចម្តេច?

ការផ្តល់អំណាចឱ្យស្ត្រី គឺមានន័យថា ជាការបង្កើតឱកាសគ្រប់គ្រាន់លើជីវិតខ្លួនផ្ទាល់ វាមានន័យថា :

- អំណាចក្នុងការធ្វើសេចក្តីសំរេច
- អំណាចក្នុងការធ្វើឱ្យសំលេងមានប្រសិទ្ធភាព
- អំណាចក្នុងការបញ្ចូលគំនិតទៅក្នុងរបៀបវារៈ
- អំណាចក្នុងការចរចាស្ថានការណ៍ថ្មីៗ
- អំណាចផ្ទាល់ខ្លួនក្នុងការជំទាស់នឹងទំនៀមទម្លាប់ចាស់ៗ

## ៧៥. តើត្រូវមានវិធានការពិសេសអ្វីខ្លះដើម្បីបង្កើនចំនួនតំណាងរាស្ត្រស្ត្រីនៅអាណត្តិទី៥នេះ?

- **"ប្រព័ន្ធកូតា"** ជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយដែលអាចលើកទឹកចិត្តឱ្យគ្រប់គណបក្សនយោបាយដាក់បេក្ខជនស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ការលើកទឹកចិត្តដើម្បីបង្កើតប្រពន្ធ័កូតាក្នុងគណបក្សក៏អាចត្រូវបានបង្កើតក្នុងក្របខណ្ឌច្បាប់ដែរ គឺនិយាយដល់ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត។ វិសោធនកម្មច្បាប់នេះ កែលម្អបន្ថែមលក្ខណៈនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណ-បក្សនយោបាយដែលតម្រូវឱ្យមានប្រពន្ធ័កូតាស្ត្រី *៣០%* និងដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី-បុរសតាំងពីលេខរៀងទី១ទៅ។
- **បង្កើតគោលនយោបាយសម្រាប់រដ្ឋផ្តល់មូលនិធិដល់គណបក្សនយោបាយ**ណាដែលគោរព និងអនុវត្តតាមច្បាប់ ដោយដាក់បេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀង

ខាងលើ ឬឆ្លាស់គ្នារវាងបេក្ខជនស្ត្រី-បុរស៣០%។ មូលនិធិរបស់រដ្ឋត្រូវបាន អនុមត័ចេញពីថវិកាជាតិដើម្បីឱ្យទៅគណបក្សនយោបាយសម្រាប់ធ្វើការបណ្តុះបណ្តាលដល់បេក្ខជន ពិសេសបេក្ខនារីក្នុងកិច្ចការនយោបាយ និងការបោះឆ្នោត។

- ដើម្បី**បង្កើតបរិយាកាសល្អប្រសើរ**សំរាប់ស្ត្រី និង**ធានានូវសុវត្ថិភាព**សម្រាប់បេក្ខនារី រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងគ.ជ.បបន្តអនុវត្តន៍ឱ្យបានតឹងរ៉ឹងនូវវិធានការពិសេស និងអន្តរាគមន៍ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែង បំភិតបំភ័យនិងអំពើហឹង្សាលើអ្នកបោះឆ្នោតស្ត្រី បេក្ខនារី និងសកម្មជនស្ត្រីនយោបាយ។
- **ប្រពន្ធ័ផ្សព្វផ្សាយ**ផ្តោតការ *អប់រំ* ដល់អ្នកបោះឆ្នោតអំពី សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងពង្រឹងការទទួលបានការ *ផ្សព្វផ្សាយដោយស្មើភាព* របស់បេក្ខជនស្ត្រី។
- **ប្រជាពលរដ្ឋកម្ពុជាដែលមានសិទ្ធិ**បោះឆ្នោតទាំងស្ត្រី និងបុរស សូមទៅបោះឆ្នោតកុំបីខាន ដោយសម្រេចចិត្ត*បោះឆ្នោតឱ្យគណបក្ស*ដែលមានបេក្ខភាពស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើ។

## ៧៦_ តើត្រូវធ្វើដូចម្តេចដើម្បីរក្សាចំនួនស្ត្រីជាប់ឆ្នោត និងបង្កើនចំនួនស្ត្រីនៅថ្នាក់សម្រេចចិត្តកាន់តែច្រើន?

ជាក់ស្តែងចំនួនស្ត្រីជាប់ឆ្នោតគឺមានតិច ប៉ុន្តែអ្វីជាការព្រួយបារម្ភនៅពេលស្ត្រីជាប់ឆ្នោតណាម្នាក់លាលែងពីតំណែងបែរជាត្រូវជំនួសតំណែងដោយបុរស។ ដូច្នេះ ដើម្បីរក្សាចំនួនស្ត្រីជាប់ឆ្នោត និងបង្កើនចំនួនស្ត្រីនៅថ្នាក់សម្រេចចិត្តកាន់តែច្រើននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន គណបក្សនយោបាយគួរតែពិចារណាពីរបៀប ឬនីតិវិធីដែលអាចរក្សាការពារចំនួនស្ត្រីជាប់ឆ្នោត និងផ្តល់ឱកាសដល់ស្ត្រីជំនួសបុរសជាប់ឆ្នោតដែលបានលាលែង

ពីតំណែង។ បើករណីមានស្ត្រីជាប់ឆ្នោតណាម្នាក់ត្រូវបានលាលែងពីតំណែងដោយមូល-ហេតុផ្សេងៗ ត្រូវតែមានស្ត្រីផ្សេងមកជំនួស។ ផ្ទុយមកវិញ បើករណីបុរសត្រូវលាលែងពីតំណែងគួរតែយកស្ត្រីមកជំនួសផងដែរ។

**មានស្ត្រីច្រើន មានអំណាច មានការដោះស្រាយ !**

# ផ្នែកទី៥

# យុវជន និងនយោបាយ

## ៧៧_ តើមនុស្សប្រភេទណាដែលគេចាត់ទុកជាយុវជន_យុវនារី?

គឺជាក្រុមមនុស្សដែលមានវ័យក្មេងៗពោរពេញដោយថាមពល ទាំងកាយ និងបញ្ញា។ ពួកគេជាក្រុមមនុស្សដែលងាយមានការផ្លាស់ប្តូរ ដែលការផ្លាស់ប្តូរទាំងនោះអាស្រ័យទៅតាមបរិស្ថានជុំវិញពួកគេ។ ក៏ប៉ុន្តែក្រុមមនុស្សទាំងនេះ ត្រូវបានគេកំណត់អាយុខុសៗគ្នាទៅតាមអង្គភាព ឬ តំបន់ ឬ ទៅតាមប្រទេសខុសៗគ្នាដូចជា[១] ÷

- ប្រទេសកម្ពុជា ក្រសួងអប់រំបានកំណត់យកយុវជនចាប់ពី១៥ឆ្នាំ ទៅ៣០ឆ្នាំ។ រីឯសមាគមយុវជនខ្មែរកំណត់យកពី១៦ឆ្នាំ ទៅ៣៥ឆ្នាំ។
- អង្គការសហប្រជាជាតិកំណត់យកពី ១៥ឆ្នាំ ទៅ២៤ឆ្នាំ
- ប្រទេសថៃ កំណត់ពី១៤ឆ្នាំ ទៅ២៥ឆ្នាំ

---

[១] តាមការបកស្រាយពីលោកយង់ គឹមអេង ប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងជាអតីតប្រធានសមាគមយុវជនខ្មែរ នៅឆ្នាំ២០១០

- ប្រទេសម៉ាឡេស៊ី កំណត់យកក្រុមមនុស្សអាយុក្រោម៤០ឆ្នាំ

**៧៨. តើយុវជនចាំបាច់ចូលរួមក្នុងកិច្ចការនយោបាយដែរឬទេ? ព្រោះហេតុអ្វី?**

យុវជន (ប្រុស-ស្រី) ចាំបាច់ត្រូវតែចូលរួមក្នុងវិស័យនយោបាយ។ ព្រោះយុវជនក៏ដូចជាក្រុមមនុស្សដទៃទៀតដែរ។

- មានតម្រូវការផ្ទាល់ខ្លួន
- ជាសរសរទ្រូងរបស់ជាតិ ជាកំលាំងស្នូល ជាក្រុមមានមនសិការខ្ពស់ កំលាំងកាយបរិបូរណ៍ និងមានកម្លាំងស្មារតី និងឆន្ទៈមុតមាំ។
- មានគំនិតសុទិដ្ឋិនិយមច្រើន មានទឹកចិត្តស្នេហាជាតិខ្ពស់ និងមានគំនិតច្នៃប្រឌិតថ្មីៗខុសពីអ្នកជំនាន់មុនៗដែលមានគំនិតអភិរក្សនិយមច្រើន។
- តម្រូវការខុសពីអ្នកជំនាន់មុន ដោយសារពួកគេរស់នៅក្នុងសង្គមដែលពោរពេញដោយភាពប្រែប្រួល វិវត្តន៍លឿន ជាពិសេសនាពេលបច្ចុប្បន្ននេះ។
- ធ្វើឱ្យមានការប្រែប្រួលក្នុងសង្គម នៅពេលដែលតម្រូវការរបស់ខ្លួនត្រូវបានគេមើលរំលង និងមិនបានដោះស្រាយ។
- អាចជំរុញឱ្យយុវជនក្លាយជាអ្នកដឹកនាំផងដែរ។

**៧៩. តើយុវជនគួរធ្វើយ៉ាងណាដើម្បីឱ្យខ្លួនមានតំលៃក្នុងសង្គម?**

- ទោះមានចំណេះដឹងជ្រៅជ្រះ ឬ តិចតួច ឬ មិនមានក្តី យុវជនត្រូវតែធ្វើ**អត្តចរិតឱ្យបានសមជាពលរដ្ឋល្អ**។
- យុវជន ត្រូវតែព្យាយាមធ្វើការ**តាមដាន**រាល់ការដឹកនាំរបស់អ្នកនយោបាយអ្នកដឹកនាំ ហើយត្រូវចេះ**លើកយកបញ្ហា**ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិមកធ្វើការជជែកពិភាក្សាជាមួយក្រុម ឬ អង្គការ សមាគមយុវជនដទៃទៀត ឬ ជាមួយអ្នកនយោបាយតាមគ្រប់មធ្យោបាយដូចជា **ចូលរួម**ក្នុងវេទិកានានាដែល

រៀបចំឡើងដោយអង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងរដ្ឋាភិបាលជាដើម

- យុវជនត្រូវតែ**ធ្វើជាមនុស្សគំរូ**ដល់អ្នកជំនាន់បន្ទាប់ៗ ក្នុងការចូលរួមកិច្ចអភិវឌ្ឍន៍សង្គម ការប្រឆាំងនឹងអំពើឧបាយមុខដូចជា ការជួញដូរមនុស្ស ការសេពគ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសង និងចូលរួមយុទ្ធប្រឆាំងអំពើពុករលួយ...
- នៅពេល**គ្រប់អាយុ១៨ឆ្នាំ** យុវជនត្រូវតែព្យាយាមបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋ គឺត្រូវ**ទៅចុះឈ្មោះ** និង**ទៅបោះឆ្នោត**ជ្រើសរើសតំណាងរបស់ខ្លួនទៅតាមឆន្ទៈ ដោយមានការពិចារណា និងថ្លឹងថ្លែងឱ្យបានហ្មត់ចត់។
- **ក្រោយពេលបោះឆ្នោត** យុវជនត្រូវតែខិតខំ**សង្កេតតាមដាន ឃ្លាំមើល**សកម្មភាពអនុវត្តរបស់មន្ត្រីជាប់ឆ្នោត រាជរដ្ឋាភិបាល ដើម្បីចូលរួមវាយតំលៃលើលទ្ធផលនៃសកម្មភាពទាំងនោះ ហើយផ្តល់ព័ត៌មានទាំងនេះទៅដល់អ្នកបោះឆ្នោតដទៃទៀតសំរាប់ធ្វើជាទុនពិចារណាក្នុងការសំរេចចិត្តបោះឆ្នោតលើកក្រោយៗទៀត។
- ខិតខំ**បង្កើនចំណេះដឹង** និង**កសាងសមត្ថភាពផ្ទាល់ខ្លួន**បន្ថែមទៀត។



**យុវជនស្រឡាញ់ជាតិ ឆ្លៀតទៅបោះឆ្នោតតាមឆន្ទៈ!**

# ផ្នែកទី៦ ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់:

# វិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន

## ៨០- តើវិមជ្ឈការនៅកម្ពុជាមានអត្ថន័យដូចម្តេច ?

- វិមជ្ឈការមានន័យថា សិទ្ធិ ការទទួលខុសត្រូវ និងធនធានមួយចំនួនត្រូវបានផ្ទេរពីរដ្ឋាភិបាលជាតិទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ។
- វិមជ្ឈការ មានបំណងលើកកំពស់លទ្ធិប្រជាធិបតេយ្យ និងកែលំអជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋទទួលបានឱកាសកាន់តែច្រើនឡើងក្នុងការធ្វើសេចក្តីសំរេចចិត្តលើបញ្ហានៅមូលដ្ឋាន ដែលប៉ះពាល់មកលើជីវភាពរស់នៅរបស់ខ្លួន។



## ៨១. កំណែទម្រង់វិមជ្ឈការនៅកម្ពុជា មានទិសដៅអ្វីខ្លះ?

កំណែទម្រង់វិមជ្ឈការនៅកម្ពុជា មានទិសដៅចំនួន បី ÷

- **ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន** (លទ្ធិប្រជាធិបតេយ្យពហុបក្សនៅមូលដ្ឋាន និងអភិបាលកិច្ចល្អ) តាមរយៈការបង្កើតអាជ្ញាធរមូលដ្ឋាន (ឃុំ-សង្កាត់) ដែលទទួលអំណាចពីប្រជាពលរដ្ឋ និងមានស្វយ័ភាព ហើយមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ជាអ្នកតំណាងឱ្យផលប្រយោជន៍ និងដោះស្រាយផលប្រយោជន៍របស់ប្រជាពលរដ្ឋ ព្រមទាំងធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សម្ភារៈបរិក្ខា និងសេវាសាធារណៈ ។
- **លើកកំពស់វប្បធម៌នៃការចូលរួម** និងអនុវត្តការអភិវឌ្ឍដោយមានការចូលរួម (ការកសាងផែនការ ការគ្រប់គ្រង ការកៀរគរធនធាននៅមូលដ្ឋាន) តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។
- **រួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ**នៅក្នុងប្រទេស តាមរយៈការកែលំអសេវា ការផ្តល់ឱកាសឱ្យជនក្រីក្រ និងជនងាយរងគ្រោះក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវា ។

## ៨២. តើគោលបំណងសំខាន់ៗនៃការគ្រប់គ្រងឃុំ-សង្កាត់តាមបែបវិមជ្ឈការមានអ្វីខ្លះ?

គោលបំណងនៃការគ្រប់គ្រងឃុំ-សង្កាត់តាមបែបវិមជ្ឈការ គឺ ÷

- លើកកំពស់ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាព
- ផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសកាន់តែច្រើន ដើម្បីសំរេចលើអនាគតរបស់ខ្លួន ។
- ធានានូវកិច្ចអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយរាប់បញ្ចូលទាំងការផ្តល់សេវា

ជាមូលដ្ឋានផង ។

- ការផ្ដល់ភាពជានីតិបុគ្គលឱ្យឃុំ-សង្កាត់
- ការបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ឃុំ-សង្កាត់
- អំណាចដឹកនាំគ្រប់គ្រងឃុំ-សង្កាត់ គឺត្រូវកើតចេញពីការបោះឆ្នោតដោយ សេរី ត្រឹមត្រូវ និងយុត្តិធម៌ក្នុងក្របខ័ណ្ឌឃុំ-សង្កាត់នីមួយៗ ។
- ការផ្ដល់នូវអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិឱ្យឃុំ-សង្កាត់
- កំណត់អំពីការរៀបចំកែសម្រួលព្រំប្រទល់ឃុំ-សង្កាត់ ។

**៨៣-** **ហេតុអ្វីបានជាការចូលរួមដោយស្មើភាពរបស់ស្ត្រី និងបុរសនៅក្នុងដំណើរការវិមជ្ឈការមានសារៈសំខាន់?**

- គោលបំណងសំខាន់របស់វិមជ្ឈការ គឺដើម្បីឱ្យកម្ពុជាឆ្លើយតបចំពោះសិទ្ធិមនុស្ស និងប្រជាពលរដ្ឋមានលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសដូចគ្នា និងទទួលផលស្មើគ្នា ។ ម្យ៉ាងទៀត ធានាឱ្យមានសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីដែលជាការបង្ហាញនូវការគោរពទៅតាមរដ្ឋធម្មនុញ្ញ និងបំបាត់អំពើរើសអើងមកលើស្ត្រី ។
- ការចូលរួមដោយស្មើភាពរបស់បុរស និងស្ត្រីនៅក្នុងកិច្ចការទាំងអស់ដែលត្រូវអនុវត្តនៅក្នុងវិមជ្ឈការ និងនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់នឹងលើកកំពស់សុខុ-មាលភាពរបស់ប្រទេសជាតិទាំងមូលនិងលើកកំពស់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ

**៨៤-** **តើវិសហមជ្ឈការមានន័យដូចម្ដេច?**

វិសហមជ្ឈការមានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតភូកម្មមុខងារ សិទ្ធិអំណាច ធនធានទៅអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន។

**៨៥-** **តើអភិបាលកិច្ចមូលដ្ឋានមានន័យយ៉ាងដូចម្ដេច?**

អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា គឺនិយាយយោងទៅ**ដំណើរការ**ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋត្រូវលើកស្ទួយធាតុសំខាន់ៗរួមមានៈ **ការចូលរួម តម្លាភាព គណនេយ្យភាព** (ការទទួលខុសត្រូវខ្ពស់) **ប្រសិទ្ធភាពការងារ មានសមភាពលើកកំពស់ការគ្រប់គ្រងដោយច្បាប់**ដែលត្រូវផ្តល់ឱកាសឱ្យជនក្រីក្រ ជនងាយរងគ្រោះក្នុងការធ្វើសេចក្តីសំរេចចិត្ត និងការទទួលសេវា ។

### ៨៦. តើតម្លាភាពនៅឃុំ-សង្កាត់មានន័យដូចម្តេច?

**តម្លាភាព មានន័យថា** ដំណើរការដែលធ្វើឱ្យមានព័ត៌មានពេញលេញដោយសេរី ។

✦ ក្រុមប្រឹក្សាត្រូវបើកចំហជូនសាធារណជន អំពី ថវិកាចំណូល ចំណាយ និងដំណើរការនៃការសំរេចចិត្ត ។

**<u>ឧទាហរណ៍:</u>** កំណត់ហេតុនៃការប្រជុំ សេចក្តីសម្រេច និងគំរោងផ្សេងៗដែលអនុម័តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវតែបិទផ្សាយជាសាធារណៈ ។ មិនតែប៉ុណ្ណោះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវផ្តល់ព័ត៌មានលក្ខណៈបើកចំហ ប្រសិនបើប្រជាពលរដ្ឋណាចង់ដឹងពីព័ត៌មាន ហើយអាចទៅរកដោយសេរី ។

### ៨៧. តើក្រុមប្រឹក្សាឃុំ-សង្កាត់ប្រជុំជាសាធារណៈនៅពេលណា? ទីណា?

- ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចចំនួនមួយដងក្នុងមួយខែ
- ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់ ឬក្នុងករណីចាំបាច់អាចប្រជុំកន្លែងផ្សេងបាន ។

### ៨៨. ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ តើប្រជាពលរដ្ឋមានតួនាទី និងភារកិច្ចអ្វីខ្លះ?

- តាមដានលទ្ធផលនៃការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេឃុំ-សង្កាត់ ។

- ត្រូវស្គាល់ឈ្មោះនិងប្រវត្តិរូបខ្លះៗរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ឆ្នោត
- ឃ្លាំមើល និងចូលរួមសកម្មភាពការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដូចជា ÷
  - តាមដានពីការសំរេចចិត្តនិងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់
  - ចូលរួមការពិភាក្សាផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់លើវិស័យសំខាន់ៗ ដូចជា អភិវឌ្ឍន៍ សន្តិសុខ អប់រំ សុខភាព ។ល។
- ឃ្លាំមើល និងវាយតម្លៃការអនុវត្តតាមកិច្ចសន្យា
- បង្កើនសាមគ្គី និងពង្រឹងបណ្តាញសង្គមស៊ីវិលនៅមូលដ្ឋាន ។




**៨៩- តើប្រជាពលរដ្ឋអាចស្នើសុំប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់បញ្ចូលបញ្ហា ឬតំរូវការមួយឬច្រើននៅក្នុងរបៀបវារៈប្រជុំរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានឬទេ?**

**ប្រជាពលរដ្ឋជួបជុំគ្នារកបញ្ហា តំរូវការចាំបាច់ក្នុងឃុំ**



- ចាប់ពី **៥០នាក់** ឡើងទៅចំពោះឃុំ សង្កាត់ដែលមានប្រជាពលរដ្ឋតិចជាង ៦ ០០០នាក់ ។
- ចាប់ពី **១០០នាក់**ឡើងទៅ

ចំពោះឃុំ-សង្កាត់ដែលមានប្រជាពលរដ្ឋចាប់ពី ៦ ០០១នាក់ ដល់ ៣០ ០០០នាក់ ។

- ចាប់ពី **១៥០នាក់**ឡើងទៅចំពោះឃុំ-សង្កាត់ដែលមានប្រជាពលរដ្ឋច្រើនជាង ៣០ ០០១នាក់ ។

ចំនួនប្រជាពលរដ្ឋដែលបានស្នើសុំខាងលើ អាចចាត់តាំងតំណាងរបស់ខ្លួនចំនួន**៣នាក់** ឱ្យ ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីចោទសួរបញ្ហា ឬការពារតម្រូវការរបស់ក្រុមខ្លួនដែលបានស្នើឡើងនោះ ។

## ៩០~ ពេលតំណាង៣នាក់របស់ក្រុមប្រជាពលរដ្ឋចោទសួរហើយ តើពេលណាទើបគេឆ្លើយតបវិញ?

- **ឆ្លើយភ្លាមៗតែម្តង** ! ពេលនោះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែធ្វើការពិចារណាលើបញ្ហា ឬតម្រូវការដែលបានស្នើដោយប្រជាពលរដ្ឋ ហើយប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវតែឆ្លើយជាបន្ទាន់ និងផ្ទាល់មាត់ ។

**ចូលរួមប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**



- ប៉ុន្តែ ក្នុងករណីមិនអាចឆ្លើយដោយផ្ទាល់មាត់បាន ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ត្រូវឆ្លើយជាលាយលក្ខណ៍អក្សរនូវសំណួរដែលប្រជាពលរដ្ឋ (តំណាង៣នាក់) បានលើកឡើង និងត្រូវធ្វើរបាយការណ៍អំពីចម្លើយនោះនៅ ក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។

## ៩១. តើប្រជាពលរដ្ឋមានសិទ្ធិអំណាចចូលរួមក្នុងដំណើរការការងារឃុំ-សង្កាត់បានដែរឬទេ ?

**ចូលរួមសកម្មភាពការងារ**



ក្នុងគំរោងអភិវឌ្ឍន៍ឃុំ-សង្កាត់ ប្រជាពលរដ្ឋត្រូវចូលរួមចំណែកជាប្រាក់បដិភាគ( លុយ) ។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋអាចចូលរួមបន្ថែមទៀតនូវសម្ភារៈ ឬគំនិតយោបល់ ឬកំលាំងពលកម្មឬបច្ចេកទេស ព្រោះថា គំរោងអភិវឌ្ឍន៍នីមួយៗអាចសំរេចបានល្អ មានគុណភាព ទាល់តែមានការចូលរួម និងទទួលខុសត្រូវពីយើងទាំងអស់គ្នា ។

## ៩២. តើប្រជាពលរដ្ឋមានសិទ្ធិតាមដាន វាយតម្លៃដែរឬទេ?

- យើងជាប្រជាពលរដ្ឋ មានសិទ្ធិចូលរួមផ្តល់យោបល់ វាយតម្លៃទៅលើការអនុវត្តគំរោងអភិវឌ្ឍន៍នៅឃុំ-សង្កាត់របស់យើងរៀងៗខ្លួន ។ វាយតម្លៃលើការអនុវត្តការសន្យារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណបក្សជាប់ឆ្នោតទៀតផង ។

**ទទួលព័ត៌មាន ឃ្លាំមើលតាមដាន និងវាយតម្លៃ**




- មាត្រា៣៥ បានការពារសិទ្ធិយើងរួចជាស្រេចដោយបានចែងថា ***"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុង ជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"*** ។

## ៩៣. តើប្រជាពលរដ្ឋធ្វើដូចម្ដេច បើពិនិត្យទាយតំលៃឃើញថាក្រុមប្រឹក្សានេះ មិនបានបំពេញ ឬគោរពតាមការសន្យា?

- ប្រជាពលរដ្ឋត្រូវចូលរួមវាយតម្លៃលើការងារ និងលទ្ធផលរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។ បើក្រុមប្រឹក្សាឃុំ-សង្កាត់ពុំសូវបានដោះស្រាយតាមតម្រូវការចាំបាច់របស់យើង ឬពុំសូវគោរពតាមការសន្យានោះ ប្រជាពលរដ្ឋគួរប្រើប្រាស់សិទ្ធិបោះឆ្នោតជ្រើសរើសតំណាងណា ឬគណបក្សណាមួយដែលយើងសង្ឃឹមថាអាចជួយយើងបាន។
- ទៅបោះឆ្នោតតាមការគិតពិចារណា តាមការចូលរួម តាមការវាយតម្លៃពីសមិទ្ធផលក្នុងឃុំ-សង្កាត់របស់យើង ទើបការបោះឆ្នោតរបស់យើងជាការសំរេចចិត្តបានត្រឹមត្រូវ និងប្រសើរជាងអ្នកទៅបោះឆ្នោតមិនបានយល់ដឹងអ្វីសោះក្នុងអាណត្តិ ៥ឆ្នាំរបស់អ្នកជាប់ឆ្នោត។

## ៩៤. តើមុខងារ ៥ សំខាន់របស់ក្រុមប្រឹក្សាឃុំ-សង្កាត់មានអ្វីខ្លះ?



## ៩៥. តើអ្វីខ្លះជារចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវនៅរចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់ ?

**ក្រុមប្រឹក្សាឃុំ-សង្កាត់**

- ឃុំ-សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ហៅថា ក្រុមប្រឹក្សាឃុំ-សង្កាត់
- ក្រុមប្រឹក្សាឃុំ-សង្កាត់មានសមាជិកពី ៥ ទៅ ១១នាក់ ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន ។
- រដ្ឋបាលឃុំ-សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ-សង្កាត់
- ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់
- ធានាឱ្យបានថាក្រុមប្រឹក្សាប្រើប្រាស់អំណាចតួនាទីនិងមុខងារដូចមានចែងក្នុងច្បាប់
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ធ្វើសហប្រតិបត្តិការជាមួយប្រជាពលរដ្ឋ ។

**ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់**

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ធានាឱ្យបានថា ក្រុមប្រឹក្សាបានប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែ
- ធានាឱ្យបានថា កិច្ចប្រជុំត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិសំរាប់កិច្ចប្រជុំ
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។

**មេឃុំ-ចៅសង្កាត់**

ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ជាមេឃុំ-ចៅសង្កាត់

- ធានាឱ្យបានថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សា
- ផ្តល់យោបល់ និងជួយក្រុមប្រឹក្សាលើការងារកសាងផែនការហិរញ្ញវត្ថុ និងការ

អនុវត្តអំណាច តួនាទី និងមុខងារដោយក្រុមប្រឹក្សា ។

- ទទួលភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាប្រគល់ជូន។

## ជំទប់ ចៅសង្កាត់រង

ជំទប់ទី១ ចៅសង្កាត់រងទី១ និងជំទប់ទី២ ចៅសង្កាត់រងទី២ ជាជំនួយការមេឃុំ ចៅសង្កាត់ ។

### ◆ ជំទប់ទី១ ចៅសង្កាត់រងទី១

- បំពេញការងារជាមេឃុំ-ចៅសង្កាត់ ក្នុងករណីដែលមេឃុំ-ចៅសង្កាត់អវត្តមាន
- ជួយមេឃុំ-ចៅសង្កាត់លើការងារហិរញ្ញវត្ថុ និងសេដ្ឋកិច្ច
- មេឃុំ-ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី១ ឬចៅសង្កាត់ទី១

### ◆ ជំទប់ទី២ ចៅសង្កាត់រងទី២

- បំពេញការងារជាមេឃុំ-ចៅសង្កាត់ ក្នុងករណីដែលមេឃុំ-ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន ។
- ជួយមេឃុំ-ចៅសង្កាត់ លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ។
- មេឃុំ-ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី២ ឬ ចៅសង្កាត់ទី២

## គណៈកម្មាធិការ

- មេឃុំ-ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់។ គណៈកម្មាធិការខាងលើនេះ អាចយកសមា-ជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួនក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន។

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដូចជាការកសាងផែនការ និងថវិកា ។
- រាយការណ៍អំពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ពន្ធ័ទៅនឹងការងារ

ឧទាហរណ៏: គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ បង្កើតឡើង ដើម្បីលើកកំពស់ដល់ការចូលរួមរបស់ស្រ្តីក្នុងការធ្វើសេចក្តីសំរេចចិត្តលើការអភិវឌ្ឍន៍ នៅមូលដ្ឋានឃុំ សង្កាត់ ។

**<u>ស្មៀនឃុំ-សង្កាត់</u>**

ស្មៀនឃុំ-សង្កាត់ ជាបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃ ជាជំនួយការក្រុមប្រឹក្សាឃុំ-សង្កាត់ មានភារកិច្ចជួយកិច្ចការឃុំ-សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ-សង្កាត់។ ស្មៀនឃុំ-សង្កាត់ដាច់ខាតត្រូវមានជំហរអព្យាក្រឹត និងមិនលំអៀងក្នុងការងាររបស់ខ្លួន។ ស្មៀនឃុំ-សង្កាត់មិនចប់អាណត្តិជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ទេ។

**៩៦-  តើមេភូមិត្រូវបានជ្រើសរើសដោយនរណា និងមានតួនាទីភារកិច្ចអ្វីខ្លះ?**

- ក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ-សង្កាត់របស់ខ្លួន ។
- មេភូមិ ត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូប និងសមាជិកមួយរូបជាជំនួយការ។
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការមេភូមិ។

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ឬ មេឃុំ-ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ ។
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន ។
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ មេឃុំ-ចៅសង្កាត់ ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

## ៩៧- តើរដ្ឋបាលឃុំ-សង្កាត់មានតួនាទីអ្វីខ្លះ?

រដ្ឋបាលឃុំ-សង្កាត់មានតួនាទី **ពីរ** គឺ :

- **តួនាទីបំរើកិច្ចការមូលដ្ឋាន** សំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់របស់ខ្លួន (**វិមជ្ឈការ**) ។
- **តួនាទីជាភ្នាក់ងារតំណាងរដ្ឋ** ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់រដ្ឋាភិបាល ឬអាជ្ញាធររដ្ឋ (**វិសហមជ្ឈការ**) ។

## ៩៨- ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ-សង្កាត់មានភារកិច្ចអ្វីខ្លះ?

- ❑ ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- ❑ រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និង មើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ ។
- ❑ លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ❑ ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និង លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។
- ❑ ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- ❑ សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់ អាធ្យាស្រ័យ

ទៅវិញទៅមក ។

- ❑ បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**៩៩_ ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ_សង្កាត់មានភារកិច្ចអ្វីខ្លះ?**

- ❑ ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។
- ❑ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាច ( ការរំលែកអំណាច )ដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់ មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។
- ❑ ប្រតិភូកម្មខាងលើត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

<u>ឧទាហរណ៏</u>: - កិច្ចការអាត្រានុកូលដ្ឋាន ( សំបុត្រកំណើត សំបុត្រអាពាហ៏ពិពាហ៏ សំបុត្រមរណភាព)

- កិច្ចការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ...

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥
# នៅថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣

**ផលិតដោយ**

ខុមហ្វ្រែល COMFREL

គណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
Committee for Free and Fair Elections in Cambodia

**ឧបត្ថម្ភដោយ:**

NORWEGIAN PEOPLE'S AID

forum syd

EUROPEAN UNION

Oxfam Novib

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងក្រោមជំនួយហិរញ្ញវត្ថុពីម្ចាស់ជំនួយទាំងនេះ ។ ខ្លឹមសារទាំងឡាយនៅក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ខុមហ្វ្រែល និងមិនឆ្លុះបញ្ចាំងពីគោលជំហររបស់ម្ចាស់ជំនួយឡើយ ។

អាសយដ្ឋាន / Address

ស្នាក់ការ ៖ ផ្ទះលេខ ១៣៨ ផ្លូវលេខ ១២២ សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
P.O.Box 1145, CCC Box 439
Phone: (023) 884 150 / 012 924 019 / 012 924 017
Fax: (855-23) 883 750, Phnom Penh
E-mail: comfrel@online.com.kh
Website: http://www.comfrel.org